## កម្មវិធីគាំទ្រសេវាអប់រំសម្រាប់កុមារនៅតំបន់ដាច់ស្រយាល
## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# កម្មវិធីបណ្តុះបណ្តាល

## ៣ថ្ងៃកន្លះ

# អ្នកសម្របសម្រួលភាសា

### ដែលត្រូវបំរើការក្នុងថ្នាក់ទី១ដើម្បីជួយកុមារមិនចេះភាសាខ្មែរបានច្បាស់និង គ្រូបង្រៀនមិនចេះនិយាយភាសាកំណើតរបស់កុមារ



### អង្គការអប់រំពិភពលោក/ខេប/ឃែរ

**ខេត្តកំពង់ចាម ប្រទេសកម្ពុជា**

**ខែឧសភា ឆ្នាំ២០០៦**

## ខ្លឹមសារសំខាន់ៗ


**សេចក្តីផ្តើម -អ្នកសម្របសម្រួលភាសា** ៣

ការបរិយាយអំពីស្ថានភាពអ្នកសម្របសម្រួលភាសា ៣

ផែនការបណ្តុះបណ្តាល គោលបំណងបណ្តុះបណ្តាល គោលបំណងជាក់លាក់ ៤

ប្រភពគំនិតអំពីខ្លឹមសារសម្រាប់ការបណ្តុះបណ្តាល ៥

**ខ្លឹមសារសង្ខេបនៃសិក្ខាសាលាបណ្តុះបណ្តាលអ្នកសម្របសម្រួលភាសា** ៦

**ថ្ងៃទី១ របៀបកុមាររៀន** ៨

ការណែនាំអោយស្គាល់គ្នា ការស្វាគមន៍ និងល្បែង Ice breaker ៨

ការបង្ហាញអំពីកម្មវិធីអ្នកសម្របសម្រួលភាសា និងសិក្ខាសាលា ៨

តើកុមារដែលមានអាយុ៦ឆ្នាំបានដឹងនិងអាចធ្វើអ្វីបានខ្លះ? ៩

តើកុមាររៀនដោយរបៀបណា? តើកុមាររៀនពីនរណាខ្លះ? ១០

**ប្រភេទនៃការសិក្សា_ចំណេះដឹង បំនិន ឥរិយាបថ/តម្លៃ ១១**

ការសិក្សាតាមរយៈភាសា-បំនិនភាសាទាំង៤ ១១

តើនឹងមានអ្វីកើតឡើងនៅពេលកុមារមិនយល់អ្វីដែលគ្រូបង្រៀនកំពុងនិយាយ? ១២

**ថ្ងៃទី២ របៀបដែលអ្នកសម្របសម្រួលភាសាអាចជួយអោយកុមាររៀន** ១៥

ការរៀបចំសម្រាប់ការសង្កេតថ្នាក់រៀន និងការសង្កេតថ្នាក់រៀន ១៥

ការសង្កេតថ្នាក់រៀន ១៥

របាយការណ៍ត្រឡប់ពីការសង្កេតថ្នាក់រៀន ១៦

ការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន-តើមានភាពខុសគ្នាចម្បងៗអ្វីខ្លះ? ១៧

ការគ្រប់គ្រងថ្នាក់រៀន-ការងារបុគ្គល ការងារក្រុមតូច និងការងារក្រុមធំ ១៨

តួនាទីអ្នកសម្របសម្រួលភាសា-១. តើអ្នកសម្របសម្រួលភាសាជួយអ្វីខ្លះដល់កុមារ? ១៩

ការស្វែងរកកុមារដែលត្រូវការជំនួយពីអ្នកសម្របសម្រួលភាសា ២០

តួនាទីអ្នកសម្របសម្រួលភាសា-២. តើអ្នកជំនួយថ្នាក់រៀនអាចជួយអ្វីខ្លះដល់គ្រូបង្រៀន? ២១

តួនាទីអ្នកសម្របសម្រួលភាសា-៣. នៅក្រៅថ្នាក់រៀន និង សាលារៀន ២៣

**ថ្ងៃទី៣ ការធ្វើការងារជាក្រុមក្នុងការបង្រៀន** **២៥**
ការស្វាគមន៍ចំពោះគ្រូបង្រៀន និងការណែនាំអោយស្គាល់គ្នា ២៥
ការធ្វើការងារជាក្រុម-តើអ្វីដែលធ្វើអោយក្លាយជាក្រុមល្អ? ២៥
អ្នកលេងនៅក្នុងក្រុមបង្រៀន-គ្រូបង្រៀន និងអ្នកសម្របសម្រួលភាសា ២៦
ការយល់ដឹង និងការគោរពដល់ភាពខុសគ្នាខាងវប្បធម៌ ២៨
ការទំនាក់ទំនងពហុវប្បធម៌ និងការសិក្សាពីគ្នាទៅវិញទៅមក ២៩
ការធ្វើការងារជាមួយកុមារថ្នាក់ទីមួយ ៣១
កុមារដែលអាចទទួលផលប្រយោជន៍ពីការជួយរបស់អ្នកសម្របសម្រួលភាសា ៣២

**ថ្ងៃទី៤ អ្នកសម្របសម្រួលភាសា អេស្កាប់ និងសមាគមន៍យុវជនឥស្លាមកម្ពុជា** **៣៤**
អ្វីដែលធ្វើអោយកុមារចូលចិត្តមកសាលារៀន-បញ្ញត្តិនៃបរិស្ថានសិក្សាបែបកុមារមេត្រី ៣៤
ការគាំទ្ររបស់អេស្កាប់ចំពោះអ្នកសម្របសម្រួលភាសា ៣៥
តួនាទីសមាគមន៍យុវជនឥស្លាមកម្ពុជាជាដៃគូរបស់អេស្កាប់ ៣៧
ដំណោះស្រាយនៅពេលមានបញ្ហា អ្នកដែលអាចជួយអ្នកសម្របសម្រួលភាសា ៣៧
ការសរសេរអំពីការបរិយាយតួនាទីការងារ ៣៨
ការគិតគូរដល់អ្នកសម្របសម្រួលភាសានៅថ្ងៃអនាគត ៤០
ការវាយតម្លៃវគ្គបណ្តុះបណ្តាល ៤១

## ឯកសាររបស់សិក្ខាកាម ៤៤

# អ្នកសម្របសម្រួលភាសា
# (BCA)

## ការពិពណ៌នាអំពីស្ថានភាពទូទៅ

អេស្កាប់នឹងផ្តល់អ្នកសម្របសម្រួលភាសាដល់សាលារៀន ដែលបានជ្រើសរើសអន្តរាគមន៍នេះនៅក្នុងផែនការអភិវឌ្ឍន៍កម្រងសម្រាប់ឆ្នាំ២០០៥-២០០៦។ សាលារៀនដែលបានជ្រើសរើសអន្តរាគមន៍នេះស្ថិតនៅក្នុងខេត្តកំពង់ចាម។ ភាសាកំណើតរបស់កុមារនៅក្នុងសាលារៀនទាំងនេះគឺភាសាខ្មែរ-ឥស្លាម។

នៅពេលថ្មីៗនេះសមាគមន៍យុវជនឥស្លាមកម្ពុជា (CIYA) បានស្វែងរកអ្នកសម្របសម្រួលភាសាតាមរយៈការទស្សនកិច្ច និងការពិភាក្សាជាមួយសហគមន៍ខ្មែរ-ឥស្លាមក្នុងស្រុកពញាក្រែក និងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសមានៈ

១. យល់ដឹងពីភាសាខ្មែរ និងភាសាខ្មែរ-ឥស្លាមបានល្អ
២. មានចំណាប់អារម្មណ៍ធ្វើការជាមួយកុមារតូចៗ
៣. មានការតាំងចិត្តធ្វើការរយៈពេល៤ម៉ោងក្នុងមួយថ្ងៃនូវរៀងរាល់ថ្ងៃសិក្សារបស់សាលារៀនក្នុងឆ្នាំសិក្សា២០០៥-២០០៦ ដែលចាប់ផ្តើមពីខែមេសាដល់ខែកក្កដា។
៤. មានការគាំទ្រពីអ្នកដឹកនាំសហគមន៍

បេក្ខជនមិនមានការកំណត់អាយុជាក់លាក់ទេ ដែលក្នុងនោះស្ត្រីមានអាទិភាពខ្ពស់ក្នុងការជ្រើសរើស។

បេក្ខជនដែលបានជ្រើសរើសជាអ្នកសម្របសម្រួលភាសា នឹងត្រូវទទួលបានការបណ្តុះបណ្តាលរយៈពេលបីថ្ងៃកន្លះ នៅចុងខែមីនា និងត្រូវចាប់ផ្តើមបម្រើការភ្លាមបន្ទាប់ពីនោះ។

អ្នកសម្របសម្រួលភាសានឹងបម្រើការរយៈពេល៤ម៉ោងក្នុងមួយថ្ងៃ ដែលមាន៦ថ្ងៃក្នុងមួយសប្តាហ៍សម្រាប់រយៈពេលដែលនៅសល់ក្នុងឆ្នាំសិក្សា២០០៥-២០០៦នេះ។

អ្នកសម្របសម្រួលភាសានឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន**១៥ដុល្លាអាមេរិកក្នុងមួយខែ**។

## សាលារៀនដែលត្រូវជ្រើសរើស

សាលារៀនដែលបានចូលរួមត្រូវមានលក្ខណៈដូចខាងក្រោម

- បានជ្រើសរើសអន្តរាគមន៍អ្នកសម្របសម្រួលភាសានេះនៅក្នុងផែនការអភិវឌ្ឍន៍កម្រង
- មានសមាមាត្រសិស្សខ្មែរ-ឥស្លាមកម្រិតខ្ពស់
- មានការគ្រប់គ្រងបានល្អ
- មានការគាំទ្រច្រើនពីសហគមន៍

ជាបន្ថែម សាលារៀនទាំងនេះត្រូវបានអេស្កាប់ជ្រើសរើសជាតំបន់ករណីសិក្សា។

សាលារៀនចំនួន៧ នឹងចូលរួមអនុវត្តអន្តរាគមន៍នេះដែលមានអ្នកសម្របសម្រួលភាសាចំនួន១១នាក់ត្រូវបានជ្រើសរើស។

## ផែនការបណ្តុះបណ្តាល

ក្រុមគ្រូឧទ្ទេសនឹងផ្តល់នូវការបណ្តុះបណ្តាលរយៈពេលបីថ្ងៃកន្លះ។ ក្នុងរយៈពេលពីរថ្ងៃដំបូងនឹងធ្វើជាមួយអ្នកសម្រប-សម្រួលភាសា ថ្ងៃទីបីនឹងធ្វើជាមួយអ្នកសម្របសម្រួលភាសានិងគ្រូបង្រៀនដែលពួកគាត់នឹងទៅធ្វើការជាមួយ ចំណែកនៅថ្ងៃទី ៤ មានរយៈពេលពាក់កណ្តាលថ្ងៃគឺធ្វើជាមួយអ្នកសម្របសម្រួលភាសាម្តងទៀត។

ផែនការសង្ខេបសម្រាប់ការបណ្តុះបណ្តាលនឹងបង្ហាញជូនក្នុងទំព័រទី៤-៥ខាងក្រោម។

## គោលបំណងវគ្គបណ្តុះបណ្តាល

រៀបចំឱ្យមានអ្នកសម្របសម្រួលភាសា ដើម្បីឱ្យពួកគាត់អាចធ្វើការជាក្រុមជាមួយគ្រូឈរថ្នាក់ ក្នុងការជួយបង្កើនលទ្ធផលការសិក្សាសម្រាប់កុមារដែលមិនចេះភាសាខ្មែរនៅថ្នាក់ទីមួយ។

## គោលបំណងជាក់លាក់

- ដោយការបង្កើតឱ្យមានបរិស្ថានសិក្សាថ្នាក់កុមារមេត្រីបន្ថែមទៀត បានបង្កើននូវវត្តមាន និងការសិក្សារបស់កុមារដែលមិននិយាយភាសាខ្មែរជាភាសាទីមួយ។

- ដើម្បីផ្តល់ឱ្យកុមារដែលមិនចេះភាសាខ្មែរជាភាសាទីមួយ   បានយល់ហើយអាចបំពេញកិច្ចការសិក្សាផ្សេងៗក្នុងថ្នាក់រៀនបានប្រសើរឡើង។
- ដើម្បីបណ្តុះនូវមូលដ្ឋានសម្រាប់ការបង្រៀនជាក្រុមឱ្យមានប្រសិទ្ធភាព
- ដើម្បីបង្កើនការចូលរួមរបស់សមាជិកសហគមន៍ក្នុងកម្មវិធីសិក្សាសាលារៀន
- ដើម្បីបង្កើនការយល់ដឹងពីវប្បធម៌ចម្រុះដែលមាននៅក្នុងសាលារៀន

## ប្រភពគំនិតអំពីខ្លឹមសារសម្រាប់ការបណ្តុះបណ្តាល

(បានមកពីការការប្រជុំរវាងបុគ្គលិកអង្គការអប់រំពិភពលោកផ្នែកកម្មវិធីអេស្កាប់ និងឃែរផ្នែកកម្មវិធីអភិវឌ្ឍន៍ការអប់រំសម្រាប់កុមារតំបន់ខ្ពង់រាប ក្នុងខេត្តកំពង់ចាម កាលពីខែសីហា ឆ្នាំ២០០៥)

| តម្រូវការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួលភាសា | តម្រូវការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនជាក្រុម |
|---|---|
| • គោលបំណងការសិក្សាអប់រំ និងអត្ថប្រយោជន៍<br>• ចំណេះដឹងមូលដ្ឋានស្តីពីសិទ្ធិកុមារ និងការអប់រំសម្រាប់ទាំងអស់គ្នា<br>• ការទំនាក់ទំនងពហុវប្បធម៌<br>• ការធ្វើការងារជាក្រុម (រួមទាំងដំណោះស្រាយជម្លោះ)<br>• ការសិក្សា និងការរីកលូតលាស់របស់កុមារ<br>• ការបង្រៀន និងការសិក្សានៅសាលារៀន<br>• ការយល់ដឹងពីភាសា (សារៈសំខាន់នៃភាសាក្នុងការអប់រំ)<br>• តួនាទីអ្នកសម្របសម្រួលភាសា<br>• ការសិក្សាជាក្រុមតូច<br>• តម្រូវការពិសេសរបស់កុមារ<br>• បញ្ហាយេនឌ័រ<br>• ការកត់ត្រា<br>• ការត្រួតពិនិត្យ/វាយតម្លៃបច្ចេកទេស (ចំពោះការងារដែលពុំមានលក្ខណៈផ្លូវការ)<br>• ការអភិវឌ្ឍន៍ការសិក្សាបុគ្គល | • ការបង្រៀនជាក្រុម (រួមទាំងដំណោះស្រាយជម្លោះ)<br>• ការយល់ដឹងពីភាសា<br>• ការទំនាក់ទំនងពហុវប្បធម៌<br>• ការធ្វើការងារជាមួយឪពុកម្តាយសិស្ស និងសហគមន៍<br>• ការយល់ដឹងពីពហុវប្បធម៌ (ជំនឿ តាក់សូណូមីនៃរុក្ខជាតិ និងសត្វ ក្រុមអាហារ វិចនានុក្រមរូបភាពរបស់កម្មវិធីអប់រំកុមារតំបន់ខ្ពង់រាបឈ្មោះថា Junior Picture Dictionary<br>• ការរស់នៅក្នុងតំបន់ដាច់ស្រយាល |

គំនិតជាច្រើនដែលលើកឡើង ពឹងផ្អែកលើបទពិសោធន៍ការងារជាមួយអ្នកជំនួយគ្រូពីរភាសាក្នុងសាលារៀនជនជាតិដើមភាគតិចនៅក្នុងដែនដីភាគខាងជើងប្រទេសអូស្ត្រាលី និងវគ្គបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថាន Batchelor នៃការអប់រំតំបន់ជនជាតិដើមភាគតិច ,Batchelor,N.T. Australia ។

## ខ្លឹមសារសង្ខេបនៃសិក្ខាសាលាបណ្តុះបណ្តាលអ្នកសម្របសម្រួលភាសា ( ៣ ថ្ងៃកន្លះ )

| ថ្ងៃ | ប្រធានបទចម្បង | ដំណាក់កាលបង្រៀន ខ្លឹមសារចម្បង និងសំនួរគន្លឹះ | ម៉ោង | សកម្មភាពសិក្សាចម្បង |
|---|---|---|---|---|
| ១ | របៀបកុមាររៀន | ១. ការណែនាំឱ្យស្គាល់គ្នា ការស្វាគមន៍ និងល្បែង Ice breaker | ៣០ នាទី | ការណែនាំឱ្យស្គាល់គ្នា ល្បែងណែនាំឱ្យស្គាល់គ្នា |
| | | ២. ការបង្ហាញអំពីកម្មវិធីអ្នកសម្របសម្រួលភាសា និងសិក្ខាសាលា | ៣០ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស |
| | | ៣. តើកុមារដែលមានអាយុ៦ឆ្នាំបានដឹងនិងអាចធ្វើអ្វីបានខ្លះ? | ៦០ នាទី | ការពិភាក្សាក្រុមតូច និងការសរសេរលើប័ណ្ណ |
| | ( អ្នកសម្រប-សម្រួលភាសា ) | ៤. តើកុមាររៀនដោយរបៀបណា? តើកុមាររៀនពីនរណាខ្លះ? | ៦០ នាទី | ការពិភាក្សាក្រុមតូច និងការសរសេរលើប័ណ្ណ |
| | | ៥. ប្រភេទនៃការសិក្សា-ចំណេះដឹង បំនិន ឥរិយាបថ/តម្លៃ | ៣០ នាទី | ក្រុមធំធ្វើចំណាត់ថ្នាក់ប័ណ្ណដែលយកពីដំណាក់កាលបង្រៀនទី៦ |
| | | ៦. ការសិក្សាតាមរយៈភាសា-បំនិនភាសាទាំង៤ | ៤៥ នាទី | ការបង្ហាញ និងលំហាត់ចំណាត់ថ្នាក់ប្រភេទ |
| | | ៧. តើនឹងមានអ្វីកើតឡើង ពេលកុមារមិនយល់អ្វីដែលគ្រូបង្រៀនកំពុងនិយាយ? | ៦០ នាទី | ការពិភាក្សាក្រុម ការរិះគិតថ្មី និងការរាយការណ៍ |
| | | សរុបថ្ងៃទី១: **៥ម៉ោង១៥នាទី** | | |
| ២ | របៀបដែលអ្នកសម្រប-សម្រួលភាសាអាចជួយឱ្យកុមាររៀន | ១. ការរៀបចំសម្រាប់ការសង្កេតថ្នាក់រៀន | ៣០ នាទី | ការរៀបចំសម្រាប់ការសង្កេតថ្នាក់រៀន |
| | | ២. ការសង្កេតថ្នាក់រៀន...... | ៣០ នាទី | សង្កេតថ្នាក់ទីមួយ |
| | | ៣. របាយការណ៍ត្រឡប់ពីការសង្កេតថ្នាក់រៀន | ៣០ នាទី | ការពិភាក្សា និងការរិះគិតថ្មីអំពីការសង្កេត |
| | | ៤. ការសិក្សានៅផ្ទះ និងសាលារៀន-តើមានភាពខុសគ្នាចម្បងៗអ្វីខ្លះ? | ៦០ នាទី | ការបង្ហាញ និងលំហាត់ពិភាក្សាក្រុមតូច |
| | | ៥. ការគ្រប់គ្រងថ្នាក់រៀន-ការងារបុគ្គល ការងារក្រុមតូច និងការងារក្រុមធំ | ៤៥ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស ការពិភាក្សា ការរិះគិតថ្មី |
| | ( អ្នកសម្របសម្រួលភាសា) | ៦. តួនាទីអ្នកសម្របសម្រួលភាសា-១. តើអ្នកសម្របសម្រួលភាសាជួយអ្វីខ្លះដល់កុមារ? | ៣០ នាទី | ការពិភាក្សាក្រុមតូច ការកត់ត្រា និងការបង្ហាញគំនិតរបស់សិក្ខាកាម |
| | | ៧. ការស្វែងរកកុមារដែលត្រូវការជំនួយពីអ្នកសម្របសម្រួលភាសា | ៤៥ នាទី | ការពិភាក្សាក្រុមធំ និងការរិះគិតថ្មី |
| | | ៨. តួនាទីអ្នកសម្របសម្រួលភាសា-២. តើអ្នកសម្របសម្រួលភាសាអាចជួយអ្វីខ្លះដល់គ្រូបង្រៀន? | ៤៥ នាទី | ការពិភាក្សាក្រុមធំ និងការរិះគិតថ្មី |

| | | | | |
|---|---|---|---|---|
| | | ៩. តួនាទីអ្នកសម្របសម្រួលភាសា-៣. នៅក្រៅថ្នាក់រៀន និងសាលារៀន | ៤៥ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស ការពិភាក្សាក្រុមធំ |
| | | សរុបថ្ងៃទី២: ៦ ម៉ោង | | |
| ៣ | ការធ្វើការងារជាក្រុមក្នុងការបង្រៀន (អ្នកសម្រប-សម្រួលភាសា និងគ្រូបង្រៀន) | ១. ការស្វាគមន៍ចំពោះគ្រូបង្រៀន និងការណែនាំឱ្យស្គាល់គ្នា | ៣០ នាទី | ល្បែងសម្រាប់ណែនាំឱ្យស្គាល់គ្នា |
| | | ២. ការធ្វើការងារជាក្រុម-តើអ្វីដែលធ្វើឱ្យក្លាយជាក្រុមល្អ? | ៤៥ នាទី | កិច្ចការក្រុមធំ |
| | | ៣. អ្នកលេងនៅក្នុងក្រុមបង្រៀន-គ្រូបង្រៀន និងអ្នកសម្របសម្រួលភាសា | ៤៥ នាទី | ការអាន និងការពិភាក្សាក្រុមតូច |
| | | ៤. ការយល់ដឹង និងការគោរពដល់ភាពខុសគ្នាខាងវប្បធម៌ | ៣០ នាទី | ការពិភាក្សាក្រុមធំ និងការរិះគិតថ្មី |
| | | ៥. ការទំនាក់ទំនងពហុវប្បធម៌ និងការសិក្សាពីគ្នាទៅវិញទៅមក | ៦០ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស ឧទាហរណ៍របស់សិក្ខាកាម |
| | | ៦. ការធ្វើការងារជាមួយកុមារថ្នាក់ទីមួយ | ៧៥ នាទី | ការពិភាក្សាក្រុមតូច និងការធ្វើចំណាត់ថ្នាក់ |
| | | ៧. កុមារដែលអាចទទួលផលប្រយោជន៍ពីការជួយរបស់អ្នកសម្របសម្រួលភាសា | ៦០ នាទី | ការពិភាក្សាក្រុមតូច |
| | | សរុបថ្ងៃទី៣: ៥ ម៉ោង ៤៥ នាទី | | |
| ៤ | អ្នកសម្រប-សម្រួលភាសា អេស្តាប់ និងសមាគមន៍យុវជនឥស្លាមកម្ពុជា (អ្នកសម្រប-សម្រួលភាសា) | ១. តើអ្វីខ្លះដែលធ្វើឱ្យកុមារចូលចិត្តមកសាលារៀន? បញ្ញត្តិនៃបរិស្ថានសិក្សាកុមារមេត្រី | ៦០ នាទី | ការពិភាក្សាក្រុម និងការរាយការណ៍ |
| | | ២. ការគាំទ្ររបស់អេស្តាប់ចំពោះអ្នកសម្របសម្រួលភាសា-ប្រាក់ឧបត្ថម្ភ ការបណ្តុះបណ្តាល ការជួយគាំទ្រ ការគ្រប់គ្រងសហគមន៍ | ៣០ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស សំនួរ និងចម្លើយ |
| | | ៣. តួនាទីសមាគមន៍យុវជនឥស្លាមកម្ពុជាជាដៃគូរបស់អេស្តាប់ | ៣០ នាទី | ការបង្ហាញរបស់សមាគមន៍យុវជនឥស្លាម សំនួរ និងចម្លើយ |
| | | ៤. ដំណោះស្រាយពេលមានបញ្ហា អ្នកដែលអាចជួយអ្នកសម្របសម្រួលភាសា | ៣០ នាទី | ការពិភាក្សាក្រុមធំ និងការរិះគិតថ្មី |
| | | ៥. ការសរសេរពីការបរិយាយតួនាទីការងារ | ៣០ នាទី | ការពិភាក្សាក្រុមធំ |
| | | ៦. ការគិតគូរដល់អ្នកសម្របសម្រួលភាសានៅថ្ងៃអនាគត | ៣០ នាទី | ការបង្ហាញរបស់គ្រូឧទ្ទេស |
| | | ៥. ការវាយតម្លៃវគ្គបណ្តុះបណ្តាល | ៣០ នាទី | ការងារបែបចូលរួមសម្រាប់ក្រុមតូច |
| | | សរុបថ្ងៃទី៤: ៤ម៉ោង | | |

# ផែនការបង្រៀនលំអិត

## ថ្ងៃទី១:  អំពីអ្នកសម្របសម្រួលភាសា  និងសិក្ខាសាលា…

## តើកុមាររៀនដោយរបៀបណា?

**១.ការណែនាំឱ្យស្គាល់គ្នា  ការស្វាគមន៍  និងល្បែង  Ice breaker  ២០  នាទី**

**សកម្មភាពចម្បង:** ល្បែងណែនាំឱ្យស្គាល់គ្នា

**ការរៀបចំ  និងសម្ភារៈ** ប័ណ្ណរូបភាពដែលកាត់ជាពាក់កណ្តាល

**គោលបំណង:** បង្កើតបរិយាកាសរីករាយដោយឱ្យសិក្ខាកាមនិយាយគ្នា

គ្រូឧទ្ទេសស្វាគមន៍សិក្ខាកាមដែលចូលរួមក្នុងសិក្ខាសាលា។

គ្រូឧទ្ទេសប្រើប្រាស់ប័ណ្ណរូបភាពដែលកាត់ជាពាក់កណ្តាលនិងត្រូវបានសាប់ច្របល់គ្នា ហើយឱ្យសិក្ខាកាមធ្វើការជាដៃគូដើម្បីផ្គូរផ្គងចំណិតរូបភាពពាក់កណ្តាលឱ្យត្រូវគ្នា។ សិក្ខាកាមនិយាយទៅកាន់គ្នា បន្ទាប់មកណែនាំដៃគូរបស់ពួកគាត់ទៅកាន់អ្នកផ្សេងៗទៀតនៅក្នុងថ្នាក់។ នៅពេលណែនាំគ្នាត្រូវប្រាប់ព័ត៌មានផ្សេងៗដូចជា:

ឈ្មោះ អាយុ ស្ថានភាពគ្រួសារ (ឈ្មោះ និងអាយុរបស់កូន) និង

មូលហេតុដែលចង់ក្លាយជាអ្នកសម្របសម្រួលភាសា។

**២.ការបង្ហាញអំពីកម្មវិធីអ្នកសម្របសម្រួលភាសា  និងសិក្ខាសាលា  ២០  នាទី**

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស

**ការរៀបចំ  និងសម្ភារៈ:** គ្រូឧទ្ទេសឱ្យ **ឯកសារទី១** ទៅសិក្ខាកាមអំពីកម្មវិធីអ្នកសម្របសម្រួលភាសា (សន្លឹកព័ត៌មានដែលរៀបចំសម្រាប់ជាបញ្ជីសកម្មភាពកម្រង)។

**គោលបំណង:** បង្ហាញប្រាប់សិក្ខាកាមអំពីការងារជាអ្នកសម្របសម្រួលភាសា និងសិក្ខាសាលានេះ។

គ្រូឧទ្ទេសបង្ហាញព័ត៌មានដល់សិក្ខាកាមអំពីអន្តរាគមន៍អ្នកសម្របសម្រួលភាសា។ ការបង្ហាញមិនត្រូវវែងពេកទេ ប៉ុន្តែគួរបញ្ចូលចំណុចខាងក្រោម

- មូលហេតុដែលអេស្កាប់ធ្វើការជាមួយអ្នកសម្របសម្រួលភាសានៅក្នុងខេត្តកំពង់ចាម
- សាលារៀននៅក្នុងតំបន់បានជ្រើសរើសកម្មវិធីអ្នកសម្របសម្រួលភាសា និងមានការគាំទ្រពីសហគមន៍ផងដែរ។

គ្រូឧទ្ទេសបង្ហាញព័ត៌មានដល់សិក្ខាកាមនៅក្នុងសិក្ខាសាលានេះផងដែរអំពី ម៉ោង ខ្លឹមសារសំខាន់សម្រាប់ថ្ងៃនីមួយៗ វិធីសាស្ត្រ សិក្សាតាមបែបចូលរួម (សិក្ខាកាមសិក្សាដោយមានការអនុវត្តផ្ទាល់ដូចជា ការសង្កេត ការពិភាក្សា ការឆ្លើយសំនួរ ការពិភាក្សាអំពីបទពិសោធន៍របស់ពួកគាត់ ។ល ។

## ៣. តើកុមារអាយុ៦ឆ្នាំបានដឹង ឬអាចធ្វើអ្វីបានខ្លះ? ៩៥ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូច និងការសរសេរលើប័ណ្ណ

**ការរៀបចំ និងសម្ភារៈ** ប័ណ្ណសម្រាប់សរសេរ និងហ្វឹត

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមដឹងថាកុមាររៀនអ្វីៗទាំងនៅផ្ទះ និងនៅក្នុងសាលារៀន ហើយកុមារថ្នាក់ទីមួយបានរៀនចេះដឹង និង អាចធ្វើអ្វីៗបានច្រើនដោយមានបទពិសោធន៍ពីផ្ទះរបស់ពួកគេ ។

*នេះគឺជាសកម្មភាពពិភាក្សាក្រុមតូចលើកទីមួយ ។ ដោយសារសកម្មភាពនេះអាចជាសកម្មភាពថ្មីសម្រាប់សិក្ខាកាម គ្រូឧទ្ទេសអាចអង្គុយជាមួយក្រុមតូចនីមួយៗ ដើម្បីស្តាប់ការពិភាក្សា និងប្រើសំនួរដើម្បីបំផុសសិក្ខាកាម ។ គ្រូឧទ្ទេសដែលធ្វើការជាអ្នកសម្រប សម្រួលក្រុមតូចអាចជួយកត់ត្រាគំនិតរបស់សិក្ខាកាម បើសិនជាមានបញ្ហា ។*

គ្រូឧទ្ទេសប្រាប់សិក្ខាកាមឱ្យគិតអំពីកុមារនៅក្នុងថ្នាក់ទីមួយដែលពួកគាត់ទើបតែសង្កេតហើយ និងកុមារអាយុ៦ឆ្នាំផ្សេងទៀតដែលនៅតាមភូមិ ។ គ្រូឧទ្ទេសនិយាយថាសិក្ខាកាមគួរតែគិត និងសរសេររាល់អ្វីៗដែលកុមារអាយុប្រហែល៦ឆ្នាំបានដឹង ។ គ្រូឧទ្ទេសមិនត្រឹមតែប្រាប់សិក្ខាកាមឱ្យគិតអំពីអ្វីដែលកុមាររៀននៅសាលារៀនទេ ប៉ុន្តែថែមទាំងអ្វីដែលពួកគេអាចធ្វើ និងដឹងនៅផ្ទះផងដែរ ។

*បើសិនជាសិក្ខាកាមគិតមិនឃើញ គ្រូឧទ្ទេសអាចជួយដោយសួរសំនួរ (ឧ. តើកុមារទាំងអស់ដឹងពីរបៀបនិយាយឬទេ? តើពួកគេត្រូវតែមកសាលារៀនដើម្បីរៀននិយាយឬ? តើបំនិនជាក់ស្តែងអ្វីដែលពួកគេមាន-តើពួកគេចេះរត់? ចោលដុំថ្ម?...) ។ គ្រូឧទ្ទេសត្រូវធ្វើឱ្យប្រាកដថាសិក្ខាកាមមានឧទាហរណ៍អំពីគំនិតដែលកុមារដឹង/យល់ (យប់ និងថ្ងៃ ទំនាក់ទំនងគ្រួសារ) មនុស្ស ទីកន្លែង វត្ថុ ដែលពួកគេដឹង និងអាចដាក់ឈ្មោះ អ្វីៗដែលកុមារអាចធ្វើ (ឧ. ច្រៀង និយាយ រាំ រត់ ឡើងដើមឈើ) និងអារម្មណ៍/តម្លៃ (ចរិកលក្ខណៈល្អ សុភាពរាបសារ ចេះជួយចែករំលែកគ្នា ចិត្តល្អ ។ល ។ គ្រូឧទ្ទេសនឹងត្រូវការឧទាហរណ៍ទាំងអស់នេះនៅក្នុងសកម្មភាពទី៨ នៅក្នុងថ្ងៃទីមួយនេះ ។*

នៅពេលសិក្ខាកាមបានសរសេរប័ណ្ណរបស់ពួកគាត់រួចហើយ គ្រូឧទ្ទេសប្រាប់ពួកគាត់ឱ្យរៀបចម្លើយទាំងអស់នេះនៅលើក្តារខៀន ឬលើផ្ទាំងក្រដាសធំ។

**សម្រាកពេលព្រឹក**

## ៤. តើកុមាររៀនដោយរបៀបណា? តើកុមាររៀនពីនរណាខ្លះ? ៦០ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូច និងការសរសេរលើប័ណ្ណ

**ការរៀបចំ និងសម្ភារ:** ប័ណ្ណ (ពណ៌ពីរប្រភេទ) ហ្វឺត

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមដឹងថាមានមធ្យោបាយ/របៀបជាច្រើនដែលកុមាររៀនសូត្រ (មិនមែនតែពីគ្រូទេ) កុមាររៀនចេះច្រើនពីមនុស្សពេញវ័យដែលពួកគេជឿជាក់ និងស្គាល់បានច្បាស់ កុមាររៀនពីគ្នាទៅវិញទៅមក និងឱ្យពួកគាត់ដឹងថាកុមាររៀនពីខ្លួនពួកគេផងដែរ។

នេះគឺជាការពិភាក្សាមួយផ្សេងទៀត និងលំហាត់សរសេរលើប័ណ្ណ។ សិក្ខាកាមអាចឆ្លើយសំនួរពីរក្នុងពេលតែមួយដោយសរសេរចម្លើយលើក្រដាសពណ៌ពីរផ្សេងគ្នាសម្រាប់ **របៀប** និង **អ្នកដែលកុមាររៀនពី**។ ជាថ្មីម្តងទៀតគ្រូឧទ្ទេសអាចជួយដោយសួរសំនួរបើសិនជាសិក្ខាកាមគិតមិនឃើញ។

*សម្រាប់សំនួរអំពីរ **របៀប** ដែលកុមាររៀនគឺរបៀបសំខាន់តាមរយៈ ការមើល ការស្តាប់ ការចម្លងតាម ការព្យាយាមម្តងហើយម្តងទៀត ការលេង ការពិភាក្សា ការជួបប្រទះ (ឧ.ក្តៅ ត្រជាក់)... ប៉ះពាល់ (វិញ្ញាណទាំងប្រាំ-មើល ស្តាប់ ស្ទាប ហិតក្លិន ភ្លក់)។ សម្រាប់សំនួរអំពី **នរណា** ដែលកុមាររៀនពី គឺចម្លើយជាធម្មតាពី ឪពុកម្តាយ ជីដូនជីតា បងប្អូនប្រុស បងប្អូនស្រី មិត្តភ័ក្រ គ្រូបង្រៀន និងពីខ្លួនពួកគេផ្ទាល់...។*

នៅពេលបញ្ចប់សកម្មភាពគ្រូឧទ្ទេសសង្ខេបគំនិតសំខាន់ៗដូចខាងក្រោម

- កុមាររៀនច្រើនរហូតដល់ពួកគេមានអាយុ៦ឆ្នាំ
- ពួកគេមានចំណេះដឹង/ការស្វែងយល់ បំនិន និងរបៀបសំដែងអកប្បកិរិយាច្រើន
- ពួកគេរៀនច្រើនបំផុតពីសមាជិកគ្រួសារ មនុស្សដែលពួកគេស្គាល់ និងជឿទុកចិត្ត
- ពួកគេរៀនដោយប្រើ វិញ្ញាណទាំងប្រាំ និងតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ
- ពួកគេក៏បានរៀនពី ភាសា ការពិភាក្សា និងការស្តាប់

## ៥. ប្រភេទនៃការសិក្សា-ចំណេះដឹង បំនិន អាកប្បកិរិយា/តម្លៃ ៤៥ នាទី

**សកម្មភាពចម្បង:** លំហាត់ចំណាត់ថ្នាក់ប្រភេទដោយប្រើប្រាស់ប័ណ្ណពីសកម្មភាពដំបូង

**ការរៀបចំ និងសម្ភារ:** ប័ណ្ណដែលបានពីសកម្មភាពដំបូង

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមដឹងថាមានប្រភេទនៃការសិក្សាខុសៗគ្នា ហើយប្រភេទទាំងអស់នេះមានលក្ខណៈសំខាន់ណាស់។

គ្រូឧទ្ទេសបង្ហាញប័ណ្ណចំនួនបីក្នុងចំណោមប័ណ្ណដែលបានធ្វើនៅក្នុងសកម្មភាពទី៦។ ប័ណ្ណមួយគឺជាគំរូឧទាហរណ៍អំពី "ចំណេះដឹង" ប័ណ្ណទីពី បង្ហាញអំពី "បំនិន" និងប័ណ្ណទីបីបង្ហាញអំពី "តម្លៃ" ប៉ុន្តែគ្រូឧទ្ទេសមិននិយាយប្រាប់ពីអត្ថន័យទាំងអស់នេះទេ គឺគ្រាន់ តែបិទឧទាហរណ៍ទាំងបីនៅលើក្តារខៀនប៉ុណ្ណោះ។

បន្ទាប់មកគ្រូឧទ្ទេសបង្ហាញប័ណ្ណដល់សិក្ខាកាមនូវប័ណ្ណដែលបានសរសេរនៅក្នុងសកម្មភាពទី៦ ម្តងមួយម្តងមួយ ដោយសួរពួកគាត់ហើយឱ្យសម្រេចចិត្តថាតើវាត្រូវនឹងប្រភេទមួយណា (មិនត្រូវប្រាប់ឈ្មោះប្រភេទទាំង៣ទេនៅពេលនេះ)។

នៅពេលប័ណ្ណទាំងអស់ត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយគ្រូឧទ្ទេសសួរសិក្ខាកាម ឱ្យផ្តល់ឈ្មោះសម្រាប់ក្រុមប័ណ្ណនីមួយ។ គ្រូឧទ្ទេសសរសេរឈ្មោះក្រុមនៅផ្នែកខាងលើឱ្យបានសមស្របទៅតាមក្រុមប័ណ្ណនោះ។ ទោះបីជាសិក្ខាកាមដាក់ឈ្មោះអ្វីក៏ដោយសម្រាប់ក្រុមប័ណ្ណ វាមិនជាបញ្ហាទេ ការសំខាន់ឱ្យតែពួកគាត់បកស្រាយដោយមានទំនាក់ទំនងទៅនឹង ចំណេះដឹង បំនិន និង ឥរិយាបថ/តម្លៃ។

បើសិនជាសិក្ខាកាមនិយាយថាពួកគាត់មិនយល់ច្បាស់ទេ ចូរសួរពួកគាត់ដោយឱ្យគិតរកឧទាហរណ៍បន្ថែមទៀតសម្រាប់ប្រភេទនៃការសិក្សានីមួយៗ។

**សម្រាកអាហារថ្ងៃត្រង់**

## ៦. ការសិក្សាតាមរយៈភាសា-បំនិនភាសាទាំង៤ ៤៥ នាទី

**សកម្មភាពចម្បង:** ការបង្ហាញ និងលំហាត់ចំណាត់ថ្នាក់ប្រភេទ

**ការរៀបចំ និងសម្ភារ:** ប័ណ្ណសម្រាប់សរសេរគំនិតរបស់សិក្ខាកាម ហ្វឺត ស្កុត។

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមដឹងពីចំណុចសំខាន់នៃភាសាក្នុងការសិក្សា និងបំនិនភាសាទាំង៤

នៅក្នុងដំណាក់កាលបង្រៀននេះសិក្ខាកាមគិតអំពីភាសា និងបំនិនភាសាទាំងបួន-និយាយ ស្តាប់ អាន និងសរសេរ ។

ជាដំបូងគ្រូឧទ្ទេសឱ្យសិក្ខាកាមគិតអំពីរបៀបផ្សេងៗដែលមនុស្សប្រើប្រាស់ភាសា ។ ក្នុងពេលសិក្ខាកាមផ្តល់គំនិត គ្រូឧទ្ទេសម្នាក់ផ្សេងទៀតសរសេរចម្លើយដាក់លើប័ណ្ណ ។ *ឧ. និយាយរឿង អានកាសែត បោះឆ្នោត ឱ្យដំបូន្មានដល់កុមារ ទទួលដំបូន្មានពីមនុស្សពេញវ័យ...ចំពោះឧទាហរណ៍ទាំងឡាយ គ្រូឧទ្ទេសត្រូវប្រាកដថាមានទាក់ទងទៅនឹងបំនិនទាំងបួន* (ជាពិសេសការស្តាប់ ដែលហាក់ដូចជាត្រូវគេភ្លេច) ។ ចូរប្រមូលឧទាហរណ៍ឱ្យបានប្រហែល៣០ ។

បន្ទាប់មកឱ្យសិក្ខាកាមធ្វើចំណាត់ថ្នាក់ប័ណ្ណទាំងនោះជាក្រុម ហើយដាក់ឈ្មោះក្រុមទាំងនោះ ។ បើសិនជាពួកគាត់ដាក់ការអាន/ការសរសេរ ឬការនិយាយ/ការស្តាប់រួមគ្នា ចូរសួរពួកគាត់ថាតើពួកគាត់អាចបំបែកទៅជាក្រុមតូចៗ ។

នៅពេលសិក្ខាកាមបញ្ចប់ការធ្វើចំណាត់ថ្នាក់ គ្រូឧទ្ទេសឱ្យពួកគាត់ត្រួតពិនិត្យ ដើម្បីធ្វើការផ្លាស់ប្តូរណាមួយ(បើមាន) ។ បើសិនជាគ្រូឧទ្ទេសឃើញថាមានអ្វីមួយមើលទៅហាក់ដូចជាមិនត្រឹមត្រូវ ចូរសួរសិក្ខាកាម ឱ្យពន្យល់មូលហេតុដែលបានដាក់ចូលទៅក្នុងក្រុមនោះ ។

នៅពេលការធ្វើចំណាត់ និងការពិភាក្សាបានបញ្ចប់ គ្រូឧទ្ទេសគួរតែសរសេរមុខវិជ្ជាសំខាន់ៗទាំងបួននៅលើក្តារខៀន (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម) ហើយសួរសិក្ខាកាម ថាតើមុខវិជ្ជាមួយណាដែលកុមាររៀនដោយប្រើភាសា ។ បើសិនជាមាននរណាម្នាក់និយាយថា "គ្រប់មុខវិជ្ជាទាំងអស់" គ្រូឧទ្ទេសឱ្យពួកគាត់មានមតិយោបល់ពន្យល់ ។

គ្រូឧទ្ទេសសង្ខេបដោយនិយាយថា ភាសាដើរតួនាទីសំខាន់ក្នុងការសិក្សានៅសាលារៀន ។ ជោគជ័យរបស់កុមារនៅក្នុងការសិក្សាពឹងផ្អែកយ៉ាងខ្លាំងទៅលើបំនិនភាសាបានល្អ ក្នុងខណៈដែលពួកគេឡើងថ្នាក់កាន់តែខ្ពស់ទៅ ។

## ៧. តើមានអ្វីកើតឡើងនៅពេលកុមារមិនយល់អ្វីដែលគ្រូបង្រៀនកំពុងនិយាយ? ៦០ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុម ការរិះគិតថ្មី

**ការរៀបចំ និងសម្ភារ:** ក្រដាសវ៉ាធំ ហ្វឺត ។ តារាងធំមួយដែលបង្កើតឡើងដើម្បីកត់ត្រាគំនិតរបស់សិក្ខាកាមអំពីអារម្មណ៍ និងសកម្មភាពរបស់កុមារ និងគ្រូបង្រៀន ។

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមយល់ថា ការលំបាករបស់ភាសាអាចនាំឱ្យការសិក្សាទទួលបានលទ្ធផលអន់ គ្រូអាចវាយតម្លៃសមត្ថភាពការសិក្សារបស់សិស្ស ការជឿជាក់លើខ្លួនឯងមានកម្រិតទាប ការសំដែងអកប្បកិរិយាផ្សេងៗ មិនល្អ និងនាំឱ្យមានការបោះបង់ការសិក្សា។

គ្រូឧទ្ទេសចាប់ផ្តើមពន្យល់ និងផ្តល់សេចក្តីណែនាំជាភាសាអង់គ្លេស (ឬភាសាផ្សេងទៀតដែលសិក្ខាកាមមិនយល់)។ *ឧទាហរណ៍: ប្រទេសកម្ពុជាស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ដែលមានព្រំប្រទល់អន្តរជាតិជាប់ប្រទេសចំនួនបី។ ប្រទេសទាំងនេះមានព្រំប្រទល់នៅទិសខាងលិច ខាងកើត និងខាងជើង។ សូមសរសេរឈ្មោះប្រទេសចំនួនបីនេះនៅលើក្រដាសដែលបានផ្តល់ជូន។ សូមសរសេរឈ្មោះ និងទិស (ខាងជើង ខាងត្បូង ខាងកើត ឬខាងលិច) ដែលជាប់ព្រំប្រទល់ជាមួយប្រទេសកម្ពុជា។ (ចម្លើយ: ប្រទេសថៃនៅភាគខាងលិចនិងខាងជើង ប្រទេសឡាវនៅភាគខាងជើង និងប្រទេសវៀតណាមនៅភាគខាងកើត)។ For example: Cambodia is a country in South East Asia that has three internatiional neighbors. These other countries border Cambodia to the north, west and east. Please write down the names of the three other countries on the small piece of paper I have given you. Write the name of the country and also write the direction (north, south, east or west) in which it borders Cambodia. (Answer: Thailand to the west and north, Loas to the north, Vietnam to the east).*

គ្រូឧទ្ទេសបង្ហាញអារម្មណ៍ថាមានការរំខាន នៅពេលសិក្ខាកាមមិនធ្វើតាមអ្វីដែលគាត់កំពុងនិយាយ។ បន្ទាប់មកគ្រូឧទ្ទេសម្នាក់ទៀតពន្យល់ថានេះគឺជាការសំដែងតួ និងជាគំនិតដែលដាក់សិក្ខាកាមទៅក្នុងស្ថានភាពមួយ ដែលមិនបានដឹងថាមានអ្វីបានកើតឡើង។

គ្រូឧទ្ទេសប្រាប់សិក្ខាកាមឱ្យដាក់ខ្លួនរបស់ពួកគាត់ជាកុមារអាយុ៦ឆ្នាំ ដែលមិនយល់ពេញលេញចំពោះអ្វីដែលគ្រូកំពុងនិយាយ។ កុមារមិនអាចធ្វើអ្វីមួយបានរហ័សបន្ទាប់ពីគ្រូបានប្រាប់។ កុមារមិនអាចឆ្លើយសំនួររបស់គ្រូ។ នៅក្នុងស្ថានភាពនេះគេអាចគិតថា...

***តើកុមារមានអារម្មណ៍យ៉ាងណា?***

***តើគ្រូបង្រៀនមានអារម្មណ៍យ៉ាងណា?***

***តើកុមារនឹងធ្វើអ្វី?***

***តើគ្រូបង្រៀននឹងធ្វើអ្វី?***

គ្រូឧទ្ទេសឱ្យសិក្ខាកាមសរសេរគំនិតផ្ទាល់ខ្លួនរបស់ពួកគាត់នៅខាងក្រោមសំនួរនីមួយៗក្នុងតារាង ដែលមើលទៅមានសភាពដូចខាងក្រោម...(ឧទាហរណ៍ត្រូវបានផ្តល់ជាអក្សរទ្រេត)

| តើកុមារមានអារម្មណ៍យ៉ាងណា? | តើគ្រូបង្រៀនមានអារម្មណ៍យ៉ាងណា? | តើកុមារនឹងធ្វើអ្វី? | តើគ្រូបង្រៀននឹងធ្វើអ្វី? |
|---|---|---|---|
| *មានអារម្មណ៍ជ្រួលច្របល់ក្នុងចិត្ត* | *មានអារម្មណ៍ថាខ្លួនបរាជ័យ* | *ធ្វើពើជាយល់* | *និយាយអ្វីមួយកាន់តែខ្លាំង* |

| | | | |
|---|---|---|---|
| *ខ្វល់ខ្វាយ<br>មានអារម្មណ៍យល់ច្រឡំ<br>មានអារម្មណ៍ភ័យខ្លាច<br>មានអារម្មណ៍ថាខ្លួនល្ងីល្ងើ<br>មានអារម្មណ៍ថាខ្លួនគ្មានសមត្ថភាព* | *មានអារម្មណ៍គួរឱ្យរំខាន<br>មានអារម្មណ៍ខឹង<br>មានអារម្មណ៍ថាកុមារខ្ជិល<br>មានអារម្មណ៍ថាកុមារមិនឆ្លាត* | *ចម្លងពីកុមារផ្សេង<br>ដកថយពីមេរៀន<br>អង្គុយនៅក្រោយគេក្បែរជញ្ជាំង<br>ដើរឆាឆៅគេ<br>ទៅរកកន្លែងដេក<br>ឈប់មកសាលារៀន* | *ឡើង<br>មានការចំអកចំពោះកុមារ<br>យកកុមារធ្វើជារឿងកំប្លែង<br>ពិន័យកុមារ<br>មិនយកចិត្តទុកដាក់ចំពោះកុមារ<br>រីករាយដោយឃើញកុមារអង្គុយនៅក្រោយគេក្បែរជញ្ជាំង* |

គ្រូឧទ្ទេសនិយាយថាមានករណីជាច្រើនដែលគ្រូធ្វើការវាយតម្លៃខុសអំពីភាពវៃឆ្លាត និងអត្តចរិករបស់កុមារដោយសារតែការលំបាកខាងភាសា។

គ្រូឧទ្ទេសនិយាយទៅកាន់សិក្ខាកាមថានៅពេលពួកគាត់បង្កើតតារាងចុងក្រោយ ពួកគាត់គិតអំពីផលវិបាករយៈពេលខ្លីខាងភាសាមួយចំនួន។ ប៉ុន្តែវាក៏មានផលវិបាករយៈពេលវែងផងដែរ...។ គ្រូឧទ្ទេសឱ្យសិក្ខាកាមគិតអំពីផលវិបាករយៈពេលវែងមួយចំនួនដែលកើតចេញពីការលំបាកខាងភាសានៅក្នុងថ្នាក់បឋមសិក្សាដំបូង។ គ្រូឧទ្ទេសធ្វើការកត់ត្រាគំនិតរបស់សិក្ខាកាម...ឧ....

*កុមារមិនចូលចិត្តសាលារៀន ហើយមិនបានមករៀនទៀងទាត់ពេលវេលា*
*កុមាររៀនមិនទាន់ ហើយមានអារម្មណ៍ថាខ្លួនមិនឆ្លាតហើយក៏ឈប់ព្យាយាមរៀន*
*កុមារទទួលការប្រព្រឹត្តមិនល្អពីគ្រូបង្រៀន ហើយក៏ក្លាយជាក្មេងបង្កក់ ឬបោះបង់ការសិក្សា*
*កុមារមិនទទួលបានជោគជ័យ ត្រួតថ្នាក់ ហើយមិនបានរៀនចប់កម្រិតបឋមសិក្សា*
*កុមារត្រួតថ្នាក់ ហើយមិនបានឆ្លងភូមិសិក្សា (ទៅកម្រិតមធ្យមសិក្សាបឋមភូមិ)*

គ្រូឧទ្ទេសសន្និដ្ឋានបញ្ចប់ដោយនិយាយថាផលប៉ះពាល់មិនល្អទាំងនេះ ដូចជាកុមារមានអារម្មណ៍មិនសប្បាយចិត្តនៅសាលារៀន និងការមិនយល់បានច្បាស់ក្នុងការសិក្សាគឺជាផលប៉ះពាល់ដែលមានរយៈពេលយូ ឬអាចអស់មួយជីវិត។ ដូច្នេះការសិក្សារបស់កុមារនៅឆ្នាំដំបូងគឺមានសារៈសំខាន់ណាស់។

**ចប់ថ្ងៃទី១**

# ថ្ងៃទី២: របៀប/ចម្លោបាយដែលអ្នកសម្របសម្រួលភាសាអាចជួយឱ្យកុមាររៀន

## ១. ការរៀបចំសម្រាប់ការសង្កេតថ្នាក់រៀន ២០ នាទី

**សកម្មភាពចម្បង:** ការរៀបចំសម្រាប់ការសង្កេតថ្នាក់រៀន

**ការរៀបចំ និងសម្ភារៈ** គ្រូឧទ្ទេសផ្តល់ឯកសារទី២-ជាសន្លឹកក្រដាសសម្រាប់កត់ត្រានៅពេលធ្វើការសង្កេត និងផ្ទាំងក្រដាសធំបង្ហាញពីចំណុចសំខាន់ៗ សម្រាប់មើលនៅពេលធ្វើការសង្កេត។

**គោលបំណង:** រៀបចំឱ្យសិក្ខាកាមធ្វើការសង្កេត និងជួយពួកគាត់ឱ្យផ្តោតអារម្មណ៍លើការសង្កេត។

គ្រូឧទ្ទេសពន្យល់សិក្ខាកាមថាពួកគាត់នឹងទៅធ្វើការសង្កេតថ្នាក់ទី១។ គ្រូឧទ្ទេសពន្យល់បន្ថែមទៀតថា សិក្ខាកាមគ្រាន់តែសង្កេត មើល និងស្តាប់ ដោយមិនធ្វើការបង្រៀនទេ។ គ្រូឧទ្ទេសប្រាប់ឱ្យសិក្ខាកាមធ្វើការជាដៃគូ។ ដៃគូនីមួយៗត្រូវសង្កេតការងារក្រុមតូចរបស់កុមារដូចៗគ្នានៅក្នុងថ្នាក់រៀន។

គ្រូឧទ្ទេសនិយាយថាសិក្ខាកាមត្រូវស្តាប់ និងមើលអ្វីដែលគ្រូនិយាយ ព្រមទាំងមើលនិងស្តាប់ក្រុមកុមារដែលពួកគាត់កំពុងសង្កេត។

គ្រូឧទ្ទេសបង្ហាញផ្ទាំងក្រដាសធំដែលគាត់បានរៀបចំអំពីចំណុចសំខាន់ៗដែលត្រូវមើល។ គ្រូឧទ្ទេសនិយាយថានេះគឺជាសំនួរដែលសិក្ខាកាមនឹងពិភាក្សាបន្ទាប់ពីសង្កេតចប់:

- តើគ្រូបង្រៀនបានធ្វើការជាមួយសិស្សក្នុងថ្នាក់ទាំងមូលឬជាមួយសិស្សម្នាក់ៗ?
- តើកុមារស្តាប់បានច្បាស់នៅមុនពេលពួកគេត្រូវធ្វើអ្វីមួយឬទេ?
- តើមានកុមារខ្លះឬទេនៅក្នុងថ្នាក់ដែលមិនបានដឹងថានឹងត្រូវធ្វើអ្វី?
- តើកុមារបានធ្វើការជាក្រុមតូចឬពួកគេធ្វើការដោយខ្លួនឯង?
- តើកុមារមួយចំនួននៅក្នុងថ្នាក់បានជួយកុមារផ្សេងៗទៀតឬទេ?

## ២. ការសង្កេតថ្នាក់រៀន ៣០ នាទី

**សកម្មភាពចម្បង:** សង្កេតថ្នាក់ទី១

**ការរៀបចំ និងសម្ភារៈ** គ្រូឧទ្ទេសត្រូវរៀបចំការសង្កេតថ្នាក់រៀនមួយជាមួយនាយកសាលា និងគ្រូដែលត្រូវបង្រៀន បង្ហាញឱ្យបានមុន សិក្ខាសាលា។ គ្រូបង្រៀនដែលត្រូវបង្រៀនត្រូវប្រើប្រាស់ប្រភេទផ្សេងៗក្នុងការគ្រប់គ្រងថ្នាក់នៅក្នុងអំឡុងពេលសង្កេត ដែលរួមមាន (១) ការផ្តល់សេចក្តីណែនាំទៅកាន់ថ្នាក់ទាំងមូល (២) ការងារក្រុមតូច (៣) ការងារបុគ្គល។ វាជាការសំខាន់ផងដែរដែលគ្រូឧទ្ទេសត្រូវចូលរួមសង្កេតមេរៀនដើម្បីឱ្យដឹងថាមានអ្វីកើតឡើង ហើយ អាចជួយសិក្ខាកាមដោយការសួរសំនួរនៅក្នុងសកម្មភាពបន្ទាប់។

**គោលបំណង:** នាំសិក្ខាកាមទៅស្គាល់ថ្នាក់រៀនពិតប្រាកដ ធ្វើការសង្កេតថ្នាក់រៀន និងការស្តាប់ ផ្តល់បទពិសោធន៍ សម្រាប់សកម្មភាព នៅក្នុងសិក្ខាសាលា។

សិក្ខាកាមដើរទៅកាន់ថ្នាក់ទីមួយហើយធ្វើការសង្កេតមេរៀន។

គ្រូបង្រៀនអាចណែនាំក្រុមសង្កេតទៅកាន់សិស្សក្នុងថ្នាក់។

សិក្ខាកាមអាចយកកៅអីទៅជាមួយបើសិនជាថ្នាក់រៀនពុំមានកៅអី គ្រប់គ្រាន់។

សិក្ខាកាមអាចកត់ត្រានៅក្នុងអំឡុងពេល សង្កេត។

សូមថ្លែងអំណរគុណចំពោះគ្រូបង្រៀន និងសិស្សនៅពេលចប់ការសង្កេត។

## ៣. សេចក្តីរាយការណ៍អំពីការសង្កេតថ្នាក់រៀន ៣០ នាទី

**សកម្មភាពចម្បង:** ការរិះគិតថ្មី

**ការរៀបចំ និងសម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត

**គោលបំណង:** ផ្តល់ឱកាសឱ្យសិក្ខាកាមពិភាក្សា និងផ្តល់មតិរួមចំណែកពីការសង្កេត។ ផ្តល់ឱកាសឱ្យគ្រូឧទ្ទេសនាំសិក្ខាកាមគិតអំពីការគ្រប់គ្រង និងការរៀបចំថ្នាក់រៀន និងភាពខុសគ្នាក្នុងការសិក្សាបុគ្គល។

គ្រូឧទ្ទេសសួរសិក្ខាកាមអំពីអ្វីដែលបានឃើញនៅក្នុងការសង្កេតថ្នាក់រៀន។ នៅពេលសិក្ខាកាមផ្តល់ចម្លើយ គ្រូឧទ្ទេសម្នាក់ទៀតសរសេរចម្លើយរបស់ពួកគាត់នៅក្រោមចំណងជើងពីរលើក្រដាសធំគឺ **គ្រូ** និង **សិស្ស** ។ សិក្ខាកាមអាចប្រើកំណត់ត្រារបស់ពួកគាត់ដើម្បីផ្តល់ជាចម្លើយ ឬពួកគាត់អាចពិភាក្សាគ្នាដើម្បីផ្តល់ចម្លើយ។

គ្រូឧទ្ទេសអាចជួយសិក្ខាកាមដោយប្រើសំនួរអំពី

- តើអ្វីបានកើតឡើងនៅក្នុងមេរៀន (ឧ. មុខវិជ្ជា ជំហានការបង្រៀន កិច្ចការសិក្សា ការរៀបចំថ្នាក់រៀន ។ល។
- ថាតើកុមារទាំងអស់សំដែងអកប្បកិរិយាបែបណាមួយ (ភាពខុសគ្នាក្នុងការសិក្សាបុគ្គល)

## សម្រាកពេលព្រឹក

## ៤.ការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន - តើមានភាពខុសគ្នាអ្វីខ្លះ? ៦០ នាទី

**សកម្មភាពចម្បង:** ការគូរគំនូរជាដៃគូ ការពិភាក្សាក្រុម និងការរិះគិតថ្មី (ការធ្វើព្យុះខួរក្បាល)

**ការរៀបចំ និងសម្ភារៈ:** ក្រដាសវ៉ាមធំ ហ្វឺត តារាង

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមគិតអំពីការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន ថាតើមានភាពខុសគ្នាអ្វីខ្លះ និងអ្វីជាជំហានដ៏ធំ សម្រាប់កុមារផ្លាស់ប្តូរពីផ្ទះទៅសាលារៀន។

គ្រូឧទ្ទេសនិយាយថានៅថ្ងៃទីមួយសិក្ខាកាមបានពិភាក្សាអំពីរបៀបកុមាររៀន និងពីមនុស្សដែលគេរៀនតាម។ នៅថ្ងៃទីពីរ មានសកម្មភាពជាច្រើនអំពីការសិក្សានៅសាលារៀន។

គ្រូឧទ្ទេសប្រាប់សិក្ខាកាមឱ្យគិត និងពិភាក្សាអំពីភាពខុសគ្នាចម្បងៗរវាងការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន។ គ្រូឧទ្ទេសឱ្យសិក្ខាកាមបង្កើតជាដៃគូ បន្ទាប់មកឱ្យដៃគូនីមួយៗនូវក្រដាសផ្ទាំងធំមួយដែលបែងចែកជាពីរផ្នែក។ គ្រូឧទ្ទេសប្រាប់ដៃគូទាំងឡាយឱ្យគូររូបភាពពីរដោយប្រើហ្វឺត រូបភាពមួយគូរអំពីកុមារកំពុងសិក្សានៅផ្ទះ និងមួយទៀតកុមារកំពុងសិក្សានៅសាលារៀន (គូរជាគំនូរងាយៗ-គំនូរដំបង)។ នៅពេលពួកគាត់គូរចប់ ត្រូវយកទៅបិទលើក្តារខៀនឬជញ្ជាំង។

បន្ទាប់មកគ្រូឧទ្ទេសឱ្យសិក្ខាកាមមើលគំនូរ ហើយបង្កើតប្រយោគមួយចំនួនដោយការប្រៀបធៀបការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន។ ក្នុងពេលសិក្ខាកាមកំពុងផ្តល់ចម្លើយ គ្រូឧទ្ទេសសរសេរចម្លើយនោះដាក់ក្នុងតារាងដែលគាត់បានរៀបចំរួចហើយ (ចូរមើលខាងក្រោម ព្រមទាំងឧទាហរណ៍)។

| ការសិក្សានៅផ្ទះ | ការសិក្សានៅសាលារៀន |
|---|---|
| *កុមារអាចរៀនបានគ្រប់ពេលវេលា* | *កុមាររៀនទៅតាមម៉ោងកំនត់* |
| *កុមារអាចធ្វើអ្វីៗទៅតាមចំណូលចិត្ត ការរុករក ការលេង* | *កុមារត្រូវតែធ្វើតាមការណែនាំរបស់គ្រូបង្រៀន* |
| *កុមារមានការយកចិត្តទុកដាក់ច្រើនពីឳពុកម្តាយ បងប្អូនបង្កើត ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល* | *កុមារគឺជាមនុស្សម្នាក់ក្នុងចំណោមកុមារ៤០ ឬ៥០នាក់នៅក្នុងថ្នាក់ ដែលមិនមានការយកចិត្តទុកដាក់ជាលក្ខណៈបុគ្គលច្រើនទេ* |
| *ការសិក្សាគឺផ្សារភ្ជាប់ទៅនឹងជីវិតប្រចាំថ្ងៃ* | *ការសិក្សាផ្តោតទៅលើមុខវិជ្ជា* |

| | |
|---|---|
| *ការសិក្សាពីបទពិសោធន៍* | *ការសិក្សាពីទ្រឹស្តី* |
| *ការសិក្សាដោយមិនប្រើប្រាស់សៀវភៅសិក្សា* | *ការសិក្សាដោយប្រើសៀវភៅសិក្សា* |
| *កុមារមានសេរីភាពច្រើននៅផ្ទះ* | *កុមារធ្វើតាមវិន័យសាលារៀន* |
| *កុមារមានមនុស្សជាច្រើនថែរក្សាយកចិត្តទុកដាក់* | *កុមារមានភាពឯករាជ្យច្រើន* |
| *មនុស្សពេញវ័យទាំងអស់នៅផ្ទះស្គាល់កុមារបានច្បាស់* | *មិនមានមនុស្សពេញវ័យនៅសាលារៀនស្គាល់កុមារទេ* |
| *។ល។* | *។ល។* |

## ៥. ការគ្រប់គ្រងថ្នាក់រៀនៈ ការងារបុគ្គល ការងារក្រុមតូច និងការងារក្រុមធំ ៣០ នាទី

**សកម្មភាពចម្បងៈ** ការបង្ហាញ ការពិភាក្សា ការរិះគិតថ្មី

**ការរៀបចំ និងសម្ភារៈ** ក្រដាសផ្ទាំងធំដែលមានដ្យាក្រាមបង្ហាញពីយុទ្ធវិធីគ្រប់គ្រងថ្នាក់ផ្សេងៗគ្នា

**គោលបំណងៈ** ដើម្បីឱ្យសិក្ខាកាមស្គាល់របៀបសំខាន់ៗដែលគ្រូបង្រៀនរៀបចំសិស្សក្នុងថ្នាក់សម្រាប់ការសិក្សា និងចាប់ផ្តើមគិតអំពី តួនាទីរបស់ពួកគាត់នៅក្នុងថ្នាក់រៀន។

គ្រូឧទ្ទេសប្រាប់សិក្ខាកាមឱ្យគិតអំពីអ្វីដែលពួកគាត់បានសង្កេតនៅក្នុងថ្នាក់ទីមួយកាលពីថ្ងៃទីមួយ។ គ្រូឧទ្ទេសសួរថាៈ តើមានរបៀបផ្សេងៗគ្នាអ្វីខ្លះដែលគ្រូបង្រៀនរៀបចំថ្នាក់សម្រាប់ការសិក្សា? ចម្លើយរំពឹងទុកៈ ជាថ្នាក់ទាំងមូល ជាក្រុមតូច និងជាលក្ខណៈបុគ្គល។ បន្ទាប់មកគ្រូឧទ្ទេសបង្ហាញអ្នកសម្របសម្រួលភាសានូវដ្យាក្រាមមួយ (មើលខាងក្រោម) ដែលបានគូរនៅលើក្រដាសធំ អំពីការរៀបចំទាំងនេះ និងប្រភេទផ្សេងៗទៀត (ឧ.ដៃគូ ពាក់កណ្តាលថ្នាក់ ការសិក្សាក្រៅថ្នាក់រៀន ។ល។

| ការងារក្រុមថ្នាក់ទាំងមូល | ការងារក្រុមតូច | ការងារបុគ្គល | ការងារដៃគូ | ការងារក្រៅថ្នាក់ |
|---|---|---|---|---|
| | | | | |

បន្ទាប់មកគ្រូឧទ្ទេសសួរសិក្ខាកាមៈ *តើអ្នកគិតថាហេតុអ្វីបានជាគ្រូបង្រៀនប្រើប្រាស់ប្រភេទផ្សេងៗនៃការរៀបចំថ្នាក់រៀនក្នុងការបង្រៀន?* គ្រូឧទ្ទេសសរសេរគំនិតសិក្ខាកាមនៅលើក្តារខៀន។ គ្រូឧទ្ទេសអាចសួរសំនួរដើម្បីឱ្យសិក្ខាកាមមានគំនិតឆ្លើយ។

ចម្លើយដែលអាចកើតមានឡើងមួយចំនួនៈ

*ដើម្បីកុំឱ្យកុមារធុញទ្រាន់តាមរយៈរបៀបដដែលៗពេញមួយថ្ងៃ*

*ដើម្បីសន្សំពេលវេលា ( ការងារថ្នាក់ទាំងមូលសន្សំពេលវេលា)*

*ដើម្បីឱ្យកុមារអនុវត្តធ្វើអ្វីមួយដោយខ្លួនពួកគេ*

*ដើម្បីផ្តល់ឱកាសឱ្យកុមារនិយាយអំពីអ្វីៗក្នុងចំណោមពួកគេ*

*ដើម្បីផ្តល់ឱកាសឱ្យកុមារអនុវត្តធ្វើអ្វីមួយដោយខ្លួនឯង*

*ដើម្បីផ្តល់ទំនុកចិត្តឱ្យកុមារធ្វើអ្វីមួយដោយខ្លួនឯង*

*ដើម្បីឱ្យអ្នករៀនពូកែអាចជួយអ្នករៀនយឺត*

*ដើម្បីឱ្យកុមារមួយចំនួនអាចពន្យល់ទៅកាន់សិស្សដទៃទៀតដែលមិនយល់ភាសាខ្មែរបានច្បាស់*

ដើម្បីឱ្យដឹងថាកុមារពិតជាយល់ និងអាចធ្វើអ្វីមួយបាន

គ្រូឧទ្ទេសនិយាយថាៈ វាជាការសំខាន់ដែលយើងត្រូវដឹងអំពីមធ្យោបាយចម្រុងៗនៃការគ្រប់គ្រងថ្នាក់រៀន ពីព្រោះអ្នកសម្របសម្រួលភាសា ជានិច្ចកាលនឹងមិនធ្វើការតាមរបៀបតែមួយទេ-ពួកគេនឹងផ្លាស់ប្តូររបៀបធ្វើការដើម្បីតម្រូវទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងថ្នាក់រៀន។

| |
|---|
| **៦.តួនាទីអ្នកសម្របសម្រួលភាសា-១. តើអ្នកសម្របសម្រួលភាសាអាចជួយកុមារដូចម្តេចខ្លះ? ៣០ នាទី** |

**សកម្មភាពចម្បងៈ** ការពិភាក្សាក្រុមតូច ការកត់ត្រាគំនិត ការបង្ហាញត្រឡប់

**ការរៀបចំ និងសម្ភារៈ** ក្រដាសរ៉ាមធំ ហ្វឺត

**គោលបំណងៈ** ដើម្បីឱ្យសិក្ខាកាមគិតអំពីតួនាទីរបស់ពួកគេក្នុងការជួយកុមារឱ្យរៀន និងបង្កើតនូវឈុតសកម្មភាព។

គ្រូឧទ្ទេសនិយាយថាៈ សិក្ខាកាមនឹងធ្វើការជាអ្នកសម្របសម្រួលភាសានៅក្នុងថ្នាក់រៀនជារៀងរាល់ថ្ងៃដើម្បីជួយកុមារ និងគ្រូបង្រៀន។ នៅក្នុងដំណាក់កាលបង្រៀននេះផ្តោតទៅលើរបៀបដែលអ្នកសម្របសម្រួលភាសាអាចជួយកុមារ។ គ្រូឧទ្ទេសនិយាយថាៈ ជាលើកដំបូងនេះ ចូរគិតនិងពិភាក្សាជាក្រុមតូច-តើមានមធ្យោបាយសំខាន់ៗអ្វីខ្លះដែលអ្នកសម្របសម្រួលភាសាអាចជួយកុមារឱ្យរៀន?

ចម្លើយរំពឹងទុកៈ

*អ្នកសម្របសម្រួលភាសាអាចជួយបកប្រែ និងពន្យល់សេចក្តីណែនាំរបស់គ្រូបង្រៀនទៅកាន់សិស្សម្នាក់*

*អ្នកសម្របសម្រួលភាសាអាចធ្វើការជាមួយក្រុមដែលនិយាយភាសាដើម ដើម្បីពន្យល់សេចក្តីណែនាំ និងកិច្ចការរបស់គ្រូ*

*អ្នកសម្របសម្រួលភាសាអាចឆ្លើយតបសំនួររបស់កុមារអំពីអ្វីដែលត្រូវធ្វើ*

*អ្នកសម្របសម្រួលភាសាអាចលើកទឹកចិត្តកុមារបើសិនជាពួកគេកំពុងធ្វើកិច្ចការអ្វីមួយ ដែលពួកគេមិនមានការជឿជាក់*

*អ្នកសម្របសម្រួលភាសាអាចប្រើប្រាស់សំនួរដើម្បីជួយកុមារឱ្យដើរទៅតាមផ្លូវត្រូវ*

*អ្នកសម្របសម្រួលភាសាអាចប្រើសំនួរដើម្បីជួយកុមារគិតឱ្យបានជ្រៅអំពីអ្វីដែលកុមារកំពុងធ្វើ*

*អ្នកសម្របសម្រួលភាសាអាចស្វែងរកកុមារដែលយល់បានច្បាស់ហើយដែលអាចពន្យល់ទៅកាន់សិស្សដទៃទៀត*

*អ្នកសម្របសម្រួលភាសាអាចចង្អុលបង្ហាញ និងពន្យល់អ្វីៗនៅក្នុងសៀវភៅសិក្សាទៅឱ្យកុមារដែលមិនយល់*

*អ្នកសម្របសម្រួលភាសាអាចជួយកុមារដោយពន្យល់អ្វីៗសំដៅទៅលើផ្ទះរបស់កុមារ និងជីវភាពវប្បធម៌ដែលគ្រូបង្រៀនមិនបានដឹង ។*

នៅពេលក្រុមទាំងឡាយបានបញ្ចប់បញ្ជីគំនិតរបស់ពួកគាត់ ពួកគាត់ត្រូវបង្ហាញត្រឡប់ទៅកាន់ក្រុមថ្នាក់ទាំងមូល ។ ក្រុមតូចៗអាចបញ្ចូលគំនិតរបស់ពួកគាត់ដើម្បីបង្កើតជាបញ្ជីមួយ ។

(អ្នកសម្របសម្រួលភាសានឹងប្រើប្រាស់បញ្ជីនេះនៅថ្ងៃទី៣ដើម្បីបង្ហាញទៅកាន់គ្រូបង្រៀន)

**សម្រាកអាហារថ្ងៃត្រង់**

## ៧. ការស្វែងរកកុមារដែលត្រូវការជំនួយពីអ្នកសម្របសម្រួលភាសា ៤៥ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូចអំពីករណីសិក្សា

**ការរៀបចំ និងសម្ភារៈ:** ឯកសារអំពីករណីសិក្សា

**គោលបំណង:** ដើម្បីឱ្យអ្នកសម្របសម្រួលភាសា គិតអំពីភាពខុសគ្នាក្នុងការសិក្សារបស់កុមារនៅក្នុងថ្នាក់រៀន និងពីអ្វីដែលកុមារអាចទទួលបាននូវអត្ថប្រយោជន៍ច្រើនតាមរយៈជំនួយពីរអ្នកសម្របសម្រួលភាសា ។ លទ្ធផលពីការងារនេះអាចយកទៅប្រើប្រាស់នៅថ្ងៃទី៣ដើម្បីពិភាក្សាជាមួយគ្រូបង្រៀនឱ្យមានការស្វែងយល់អំពីតួនាទី នៃការបង្រៀនជាក្រុម ។

គ្រូឧទ្ទេសនិយាយថា: អ្នកគ្រប់គ្នាដឹងថាហេតុផលចម្បងដែលនាំឱ្យមានអ្នកសម្របសម្រួលភាសាដើម្បីធ្វើការជាមួយគ្រូបង្រៀននៅក្នុងថ្នាក់រៀនគឺ (១)ដើម្បីបង្កើតបរិយាកាសស្និទស្នាល ងាយស្រួលសម្រាប់កុមារដែលមិនចេះនិយាយភាសាខ្មែរជាភាសាកំណើត និង (២) ដើម្បីជួយកុមារទាំងអស់នេះឱ្យរៀនកាន់តែប្រសើរឡើង ។

គ្រូឧទ្ទេសនិយាយថាៈ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏មានកុមារមួយចំនួនដែលមកពីគ្រួសារនិយាយភាសាខ្មែរ-ឥស្លាមរៀនបានពូកែ ហើយកុមារមួយចំនួនទៀតដែលមកពីគ្រួសារនិយាយភាសាខ្មែរមានការលំបាកច្រើននៅសាលារៀន។ នៅក្នុងកិច្ចការនេះ សិក្ខាកាម និងគិតអំពីស្ថានភាពនៃប្រភេទកុមារផ្សេងៗនៅក្នុងថ្នាក់រៀន និងពិភាក្សាថាតើពួកគេត្រូវការអ្នកសម្របសម្រួលភាសាដើម្បីជួយ។

គ្រូឧទ្ទេសផ្តល់ឯកសារឱ្យសិក្ខាកាមដែលពណ៌នាពីប្រភេទផ្សេងៗរបស់កុមារ (ករណីសិក្សា) នៅលើក្រដាសមួយចំហៀង និងមួយចំហៀងទៀតជាចន្លោះទំនេរ។ គ្រូឧទ្ទេសឱ្យសិក្ខាកាមពិភាក្សាលើឧទាហរណ៍ដែលបានផ្តល់ឱ្យ ហើយត្រូវគិតជាក្រុមតូចថាតើអ្នកសម្របសម្រួលភាសាអាចជួយពួកគេឬទេ និងជួយតាមរបៀបណា។ សិក្ខាកាមអាចធ្វើកំណត់សំគាល់ក្នុងពេលពិភាក្សាគ្នា។ នៅពេលពួកគាត់ពិភាក្សាចប់ គ្រូឧទ្ទេសសួរក្រុមនីមួយៗឱ្យបញ្ចេញគំនិតដើម្បីរួមចំណែកគ្នា។ ក្នុងខណៈដែលអ្នកតំណាងកំពុងនិយាយ គ្រូឧទ្ទេសអាចសរសេរគំនិតរបស់ពួកគាត់នៅលើតារាងធំ ដែលគាត់បានរៀបចំបិទនៅលើក្តារខៀន។

(តារាងដែលកត់ត្រាលទ្ធផលនៅក្នុងដំណាក់កាលបង្រៀននេះ អាចនឹងយកទៅពិភាក្សាជាមួយគ្រូបង្រៀននៅថ្ងៃទី៣)

| ករណីសិក្សា | ការបរិយាយពីកុមារ | តួនាទីរបស់អ្នកសម្របសម្រួលភាសា |
|---|---|---|
| ១ | កុមារា អាយុ៧ឆ្នាំ និយាយភាសាខ្មែរ-ឥស្លាម យល់ភាសាខ្មែរបានតិចតួច ជាញឹកញាប់មិនអាចធ្វើតាមសេចក្តីណែនាំរបស់គ្រូបង្រៀនបាន កុមារនេះព្យាយាមខ្លាំងណាស់តែពុំទទួលបានជោគជ័យ | |
| ២ | កុមារី អាយុ៨ឆ្នាំ ជាកូនខ្មែរ អង្គុយនៅក្រោយគេ មិនមានការចូលរួមបានល្អ អៀនខ្មាសច្រើន មិនមានការជឿជាក់ | |
| ៣ | កុមារី អាយុ៦ឆ្នាំ ជាកូនខ្មែរ យល់ដឹងបានល្អ ជានិច្ចកាលជាអ្នកធ្វើកិច្ចការចប់ក្នុងចំណោមអ្នកមុនគេ | |
| ៤ | កុមារី ខ្មែរ-ឥស្លាម អាយុ៧ឆ្នាំ ចេះនិយាយខ្មែរខ្លះ ព្យាយាម រៀនសកម្ម អាចធ្វើការមួយចំនួនបាន | |
| ៥ | កុមារា អាយុ៦ឆ្នាំ ជាកូនខ្មែរ សកម្មខ្លាំង ធ្វើកិច្ចការគ្រប់យ៉ាងបានល្អនិងងាយស្រួល | |
| ៦ | កុមារា អាយុ៩ឆ្នាំ ជាកូនខ្មែរ អង្គុយនៅក្រោយគេ មិនបានចូលរួម មិនបានបញ្ចប់កិច្ចការច្រើន ពុំមានទ្រនាប់ជើងពាក់ | |
| ៧ | កុមារី អាយុ៦ឆ្នាំ ជាកូនខ្មែរ-ឥស្លាម មាឌតូច ស្ងៀមស្ងាត់ណាស់ ទោះបីជាធ្វើការជាក្រុមតូច មើលទៅហាក់ដូចជាភ្លេចភ្លាំង | |

| | | |
|---|---|---|
| ៨ | កុមារា អាយុ៦ឆ្នាំ និយាយភាសាខ្មែរ-ឥស្លាម និងភាសាខ្មែរ មិននិយាយ ច្រើន ប៉ុន្តែធ្វើកិច្ចការបានល្អ | |

**៤.តួនាទីអ្នកសម្របសម្រួលភាសា-២. តើអ្នកសម្របសម្រួលភាសាអាចជួយកុមារដូចម្ដេចខ្លះ? ៣០ នាទី**

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមធំ និងការរិះគិតថ្មី

**ការរៀបចំ និងសម្ភារ:** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត

**គោលបំណង:** ដើម្បីឱ្យអ្នកសម្របសម្រួលភាសាចាប់ផ្ដើមគិតអំពីរបៀបដែលពួកគាត់អាចជួយគ្រូបង្រៀន។ ដើម្បីឱ្យពួកគាត់ចាប់ផ្ដើមគិតអំពីបញ្ញត្តិនៃ "ការបង្រៀនជាក្រុម"។ ដើម្បីផ្ដល់គំនិតមួយចំនួនដែលអាចប្រើប្រាស់នៅថ្ងៃទី៣ សម្រាប់ជាការពិភាក្សាបន្ថែមទៀតជាមួយគ្រូបង្រៀន អំពីរបៀបបង្រៀនជាក្រុមអាចធ្វើការបានល្អជាមួយគ្នា។

គ្រូឧទ្ទេសនិយាយថា: អ្នកសម្របសម្រួលភាសានឹងធ្វើការនៅក្នុងថ្នាក់រៀនដើម្បីជួយកុមារឱ្យរៀនកាន់តែប្រសើរ ឡើង ប៉ុន្តែពួកគាត់ក៏អាចជួយគ្រូបង្រៀននៅក្នុងរបៀបជាច្រើនទៀត។ គ្រូឧទ្ទេសសួរសិក្ខាកាម: *តើអ្នកគិតថាអ្នកសម្របសម្រួលភាសាពីរភាសាអាចជួយគ្រូបង្រៀនបានតាមរបៀបណាខ្លះ?* ក្នុងពេលដែលសិក្ខាកាមផ្ដល់គំនិត គ្រូឧទ្ទេសសរសេរគំនិតនោះនៅលើក្ដារខៀន។ គ្រូឧទ្ទេសអាចប្រើប្រាស់សំនួរបន្ថែមទៀតផងដែរដើម្បីជួយសិក្ខាកាមបើសិនជាពួកគាត់គិតមិនឃើញ។

ចម្លើយរំពឹងទុក:

*អ្នកសម្របសម្រួលភាសាអាចជួយធ្វើការជាមួយក្រុមតូចមួយចំនួន គ្រូបង្រៀនអាចធ្វើការជាមួយក្រុមផ្សេងទៀត*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនដោយពន្យល់អ្វីៗទៅកាន់កុមារដែលមិនយល់បានច្បាស់*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនដោយប្រាប់ពួកគាត់អំពីព័ត៌មានរបស់កុមារដែលគ្រូបង្រៀនមិនបានដឹង (ឧ.ស្ថានភាពគ្រួសារ បញ្ហាគ្រួសារ បញ្ហាភាសា។ល។)*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនដើម្បីវាយតម្លៃការសិក្សារបស់កុមារដែលមិនយល់ភាសាខ្មែរបានល្អ*

*ថ្នាក់ទីមួយជាធម្មតាជាថ្នាក់ដែលមានសិស្សច្រើន ដូច្នេះអ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនទាក់ទងនឹងវិន័យក្នុងថ្នាក់រៀន*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀននៅក្នុងការគ្រប់គ្រងថ្នាក់ ឧ. ទទួលបន្ទុកគ្រប់គ្រងក្រុមសិស្សនៅក្រៅថ្នាក់ដែលកំពុងធ្វើទស្សនកិច្ចសិក្សា ឬសកម្មភាពស្រាវជ្រាវ*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនក្នុងការនាំសិស្សឱ្យសិក្សារៀនសូត្រ បើមិនដូច្នោះទេអាចនាំឱ្យរំខានដល់អ្នកដទៃ*

*អ្នកសម្របសម្រួលភាសាអាចជួយគ្រូបង្រៀនដោយប្រាប់ដំណឹងអំពីបុណ្យឬព្រឹត្តិការណ៍វប្បធម៌ ដែលគ្រូបង្រៀនមិនបានដឹង។*

(អ្នកសម្របសម្រួលភាសានឹងប្រើប្រាស់បញ្ជីនេះនៅថ្ងៃទី៣ដើម្បីរួមចំណែកជាមួយគ្រូបង្រៀន)

គ្រូឧទ្ទេសនិយាយថាបញ្ជីចម្លើយរបស់សិក្ខាកាមបង្ហាញនូវ ឧទាហរណ៍ល្អៗជាច្រើនអំពីរបៀបដែលអ្នកសម្របសម្រួលភាសា និងគ្រូបង្រៀនអាចធ្វើការរួមគ្នា និងជួយគ្នាទៅវិញទៅមកដើម្បីពង្រីកការសិក្សាដល់កុមារទាំងអស់ក្នុងថ្នាក់រៀនព្រមទាំងកុមារដែលនិយាយភាសាដើមដែលនេះគឺជាគំនិតសំខាន់មួយ។ នៅក្នុងប្រទេសផ្សេងៗទៀតដែលមានអ្នកសម្របសម្រួលភាសា និងគ្រូបង្រៀនធ្វើការរួមគ្នានៅក្នុងថ្នាក់ត្រូវបានគេហៅថា **ការបង្រៀនជាក្រុម**។ នេះគឺជាប្រធានបទដ៏សំខាន់មួយនៅថ្ងៃទី៣ នៅពេលដែលគ្រូបង្រៀនចូលរួមក្នុងសិក្ខាសាលាជាមួយអ្នកសម្របសម្រួលភាសា។

## ៩.តួនាទីអ្នកសម្របសម្រួលភាសា-៣. កិច្ចការនៅក្រៅថ្នាក់រៀន និងសាលារៀន ៤៥ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស

**ការរៀបចំ និងសម្ភារ:** តារាងបង្ហាញពីមូលហេតុមួយចំនួនអំពីកុមារមិនទៅសាលារៀន និងមិនបានបញ្ចប់ការសិក្សាកម្រិតបឋមសិក្សានៅក្នុងប្រទេសកម្ពុជា។

**គោលបំណង:** ដើម្បីបង្ហាញអ្នកសម្របសម្រួលភាសាអំពីរបៀបដែលពួកគេអាចជួយគាំទ្រការសិក្សាអប់រំ តាមរបៀបមិនផ្លូវការនៅក្រៅសាលារៀនដោយបន្ថែមទៅនឹងកិច្ចការដែលពួកគេធ្វើក្នុងថ្នាក់រៀន។

គ្រូឧទ្ទេសនិយាយថា: នៅក្នុងដំណាក់កាលបង្រៀនពីរចុងក្រោយសិក្ខាកាមបានពិភាក្សាអំពីអ្វីដែលអ្នកសម្របសម្រួលភាសាអាចជួយនៅក្នុងថ្នាក់រៀន។ ប៉ុន្តែនៅមានរបៀបផ្សេងៗទៀតដែលអ្នកសម្របសម្រួលភាសាអាចជួយកុមារ និងគ្រូបង្រៀននៅក្រៅសាលារៀន។

គ្រូឧទ្ទេសនិយាយថា: ចំពោះវត្តមានសមាជិកសហគមន៍ធ្វើការជាប្រចាំថ្ងៃនៅក្នុងសាលារៀនគឺជារបៀបមួយសំខាន់ក្នុងការជួយពង្រីកការសិក្សាអប់រំឱ្យកាន់តែទូលំទូលាយ។ គ្រូបង្រៀនជួបការលំបាកក្នុងការរក្សាទំនាក់ទំនងជាមួយឪពុកម្តាយ/គ្រួសាររបស់កុមារទាំងអស់នៅក្នុងថ្នាក់របស់គាត់ពីព្រោះថ្នាក់របស់គាត់មានសិស្សច្រើន។ សាលារៀន និងគ្រូបង្រៀនតែងតែចង់តាមដានអវត្តមាន ឬការលំបាកក្នុងការសិក្សា ប៉ុន្តែពុំមានលទ្ធភាពធ្វើដូច្នោះបាន។ បញ្ហានឹងកាន់តែលំបាកខ្លាំងឡើងនៅពេលមានកត្តាវប្បធម៌ និងភាសាពាក់ព័ន្ធ។

គ្រូឧទ្ទេសបង្ហាញតារាងនិងនិយាយថា: មានហេតុផលជាច្រើនដែលកុមារមិនអាចបញ្ចប់ការសិក្សាកម្រិតបឋមសិក្សានៅក្នុងប្រទេសកម្ពុជាបាន។ នៅទីនេះគឺជាហេតុផលមួយចំនួនដែលមានលក្ខណៈជាទូទៅ-

*កុមារមិនបានចូលរៀនកាលពីពួកគេមានអាយុ៦ឆ្នាំ (កុមារចូលរៀនយឺត អាចអាយុ៨ឬ៩ឆ្នាំ)*

*កុមារមិនចូលចិត្តសាលារៀន រៀនមិនបានពូកែ និងត្រួតថ្នាក់*

*កុមារអវត្តមានច្រើន រៀនមិនបានពូកែ និងត្រួតថ្នាក់*

*កុមារបោះបង់ការសិក្សា និងត្រួតថ្នាក់*

*កុមារបោះបង់ការសិក្សា និងមិនត្រឡប់ចូលរៀនវិញ*

*កុមារត្រួតថ្នាក់ច្រើនឆ្នាំ ហើយកាន់តែអាយុច្រើនទៅដែលនាំឱ្យមិនអាចបញ្ចប់ការសិក្សាបាន*

*គ្រួសាររបស់កុមារក្រីក្រ ដូច្នេះកុមារត្រូវជួយធ្វើការ*

គ្រូឧទ្ទេសឱ្យសិក្ខាកាមគិតថា តើមានហេតុផលទូទៅផ្សេងទៀតឬទេនៅក្នុងសហគមន៍របស់ពួកគេដែលនាំឱ្យកុមារមិនទៅសាលារៀន ឬមិនបានបញ្ចប់ការសិក្សានៅបឋមសិក្សា។ គ្រូឧទ្ទេសបន្ថែមមូលហេតុទាំងនេះទៅក្នុងតារាង។

គ្រូឧទ្ទេសនិយាយថាៈ បទពិសោធន៍នៅក្នុងប្រទេសផ្សេងៗគឺថា បើសិនជាសាលារៀន និងគ្រូបង្រៀនបង្ហាញនូវការចាប់អារម្មណ៍ចំពោះកុមារដោយមានការពិភាក្សាជាមួយគ្រួសាររបស់ពួកគេ នោះគ្រួសាររបស់កុមារមានការលើកទឹកចិត្តឱ្យកុមារមកសាលារៀន ព្រមទាំងជួយបង្រៀនកូនរបស់ពួកគេនៅផ្ទះទៀតផង។ កុមារដែលទទួលបានការលើកទឹកចិត្ត និងការជួយជ្រោមជ្រែងគេហាក់ ដូចជាស្រលាញ់ការសិក្សានៅសាលារៀន ហើយអាចឡើងថ្នាក់ពីមួយទៅមួយបានរាល់ឆ្នាំ។

គ្រូឧទ្ទេសនិយាយថាៈ អ្នកសម្របសម្រួលភាសាអាចមានប្រសិទ្ធភាពខ្លាំងក្នុងការនិយាយទៅកាន់គ្រួសាររបស់កុមារថ្នាក់ទីមួយអំពីសារៈសំខាន់នៃការលើកទឹកចិត្តកុមារឱ្យទៅសាលារៀន។ អ្នកសម្របសម្រួលភាសាមិនចាំបាច់ធ្វើរឿងនេះតាមលក្ខណៈផ្លូវការដោយការសួរសុខទុក្ខតាមផ្ទះ ឬតាមការសរសេរសំបុត្រឡើយ ពួកគាត់គ្រាន់តែធ្វើតាមរយៈ

*ការជួបគ្នាពីមួយថ្ងៃទៅមួយថ្ងៃនៅតាមផ្សារ*

*ការជួបគ្នាពីមួយថ្ងៃទៅមួយថ្ងៃនៅតាមភូមិ*

*ការជួបគ្នានៅក្នុងពិធីបុណ្យឬព្រឹត្តិការណ៍សង្គម*

*ការជួបគ្នានៅក្នុងព្រឹត្តិការណ៍វប្បធម៌...*

គ្រូឧទ្ទេសសួរសិក្ខាកាមៈ *តើអ្នកនៅចាំផ្នែកទី៤នៃសាលាកុមារមេត្រីឬទេ?* (ទំនាក់ទំនងសាលារៀន និងសហគមន៍)។ គ្រូឧទ្ទេសនិយាយថាៈ អ្នកសម្របសម្រួលភាសា អាចមានភាពសកម្មក្នុងការគាំទ្រផ្នែកនេះតាមលក្ខណៈមិនផ្លូវការនៅក្រៅសាលារៀន។

**ចប់ថ្ងៃទី២**

# ថ្ងៃទី៣: របៀបធ្វើការក្នុងការបង្រៀនជាក្រុម

នៅថ្ងៃទី៣ គ្រូបង្រៀនដែលនឹងធ្វើការជាមួយអ្នកសម្របសម្រួលភាសានឹងចូលរួមនៅក្នុងសិក្ខាសាលានេះ។ សកម្មភាពសិក្សានៅក្នុងដំណាក់កាលបង្រៀននៅថ្ងៃទី៣បូករួមទាំងអ្នកសម្របសម្រួលភាសា និងគ្រូបង្រៀន។ នៅក្នុងសកម្មភាពមួយចំនួនពួកគាត់នឹងធ្វើការជាក្រុមចម្រុះ ពួកគាត់នឹងធ្វើកិច្ចការផ្សេងៗទៀតជាក្រុមគ្រូបង្រៀន និងជាក្រុមអ្នកសម្របសម្រួលភាសា ហើយពួកគាត់នឹងធ្វើកិច្ចការមួយចំនួននៅក្នុងក្រុមបង្រៀនជាពីរនាក់ផងដែរ។

## ១. ការស្វាគមន៍គ្រូបង្រៀន និងការណែនាំឱ្យស្គាល់គ្នា ៣០ នាទី

**សកម្មភាពចម្បង:** ការណែនាំឱ្យស្គាល់គ្នាជាដៃគូ

**ការរៀបចំ និងសម្ភារៈ:** គ្មាន

**គោលបំណង:** ដើម្បីណែនាំឱ្យសិក្ខាកាមស្គាល់គ្នាទៅវិញទៅមក បង្កើតបរិយាកាសស្និទស្នាល និងឱ្យពួកគាត់ចាប់ផ្តើមជជែកគ្នា តាំងពីពេលដំបូងទៅ។

គ្រូឧទ្ទេសស្វាគមន៍ក្រុមគ្រូបង្រៀន និងណែនាំឱ្យពួកគាត់អង្គុយជាមួយអ្នកសម្របសម្រួលភាសាដែលនឹងទៅធ្វើការជាមួយពួកគាត់នៅក្នុងថ្នាក់រៀន។ ពួកគាត់ត្រូវសួរគ្នាទៅវិញទៅមកអំពីឈ្មោះដៃគូ ភូមិ ស្ថានភាពគ្រួសារ (កូន? ប្រុស/ស្រី? អាយុ?) និងអ្វីដែលពួកគាត់ចូលចិត្តធ្វើក្នុងពេលទំនេរពីការងារ (ឧ. មើលទូរទស្សន៍ លេងកីឡា ស្តាប់តន្ត្រី ធ្វើអ្វីមួយ ។ល។) បន្ទាប់មកដៃគូនីមួយៗក្រោកឈរឡើង ហើយចាប់ផ្តើមណែនាំដៃគូរបស់ខ្លួនទៅកាន់ដៃគូផ្សេងទៀត។ គ្រូឧទ្ទេសអាចណែនាំគ្នាទៅវិញទៅមក។

## ២.ការធ្វើការជាក្រុម –តើអ្វីដែលធ្វើឱ្យក្លាយជាក្រុមល្អ? ៤៥ នាទី

**សកម្មភាពចម្បង:** ការសរសេរគំនិតដាក់លើប័ណ្ណ

**ការរៀបចំ និងសម្ភារៈ:** ប័ណ្ណ ហ្វឺត ស្កុត

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមគិតអំពីការធ្វើការងារជាក្រុម និងប្រាប់ឱ្យដឹងថាក្រុមដែលល្អគឺមានលក្ខណៈជាក់ច្បាស់ និងក្រុម ដែលមានភាពកាន់តែប្រសើរឡើងគឺដោយសារការអនុវត្តផ្ទាល់។

គ្រូឧទ្ទេសនិយាយថា: គំនិតនៃមនុស្សពីរនាក់ធ្វើការរួមគ្នានៅក្នុងថ្នាក់រៀនជាក្រុមបង្រៀន គឺពិតជាគំនិតថ្មីមួយនៅក្នុងប្រទេសកម្ពុជា ទោះបីជាការធ្វើបែបនេះកើតមានជាញឹកញាប់នៅក្នុងប្រទេសជាច្រើនក្នុងពិភពលោកក៏ដោយ។ ជួនកាលក្រុមបង្រៀនកើតឡើងដោយគ្រូបង្រៀនពីរនាក់ ប៉ុន្តែជាទូទៅគឺមានតែគ្រូបង្រៀនម្នាក់ និងអ្នកសម្របសម្រួលភាសា។

គ្រូឧទ្ទេសនិយាយថា: នៅពេលនេះយើងផ្អាកការនិយាយអំពីការបង្រៀនជាក្រុមមួយរយៈសិន។ យើងគិតអំពីក្រុមកីឡាដូចជាកីឡាបាល់ទាត់ ឬក្រុមអុំទូក។ *តើចរិកលក្ខណៈក្រុមល្អ និងអ្នកលេងក្នុងក្រុមដែលល្អមានអ្វីខ្លះ? សូមសរសេរគំនិតរបស់អ្នកដាក់លើប័ណ្ណ*។ គ្រូឧទ្ទេសប្រមូលប័ណ្ណក្នុងពេលសិក្ខាកាមកំពុងសរសេរ ហើយដាក់ទៅលើក្តារខៀន។

ចម្លើយរំពឹងទុក:

*អ្នកគ្រប់គ្នាប្រឹងប្រែងយ៉ាងលំបាក*
*អ្នកលេងមានគោលបំណងដូចគ្នា*
*មានការពិភាក្សាបញ្ហាដោយចំហ*
*អ្នកគ្រប់គ្នាជួយគ្នាទៅវិញទៅមក*
*ការអនុវត្ត*
*ការហ្វឹកហាត់*
*ការជឿទុកចិត្តគ្នា*
*អ្នកលេងធ្វើផែនការរួមគ្នា*
*រាល់ទំនាស់ត្រូវបានដោះស្រាយដោយចំហ*
*ចេះរួមចំណែកបញ្ហាជាមួយគ្នា*
*ក្រុមមានលក្ខណៈធំជាងអ្នកលេង*

គ្រូឧទ្ទេសនិយាយថា: ការបង្រៀនជាក្រុមមិនមានលក្ខណៈខុសគ្នាច្រើនទេ។ វាជាការសំខាន់ដែលយើងធ្វើផែនការរួមគ្នា ក្រលេកមើលឱកាសដើម្បីជួយគ្នាទៅវិញទៅមក រួមចំណែកបញ្ហាជាមួយគ្នា ពិភាក្សាតិចនិច និងយុទ្ធសាស្ត្ររួមគ្នា។

គ្រូឧទ្ទេសនិយាយថា: ដូចនៅក្នុងក្រុមកីឡាផងដែរ ក្រុមបង្រៀននឹងមានការរីកចំរើនដោយការអនុវត្ត។ ដូច្នេះជាការសំខាន់ណាស់ដែលយើងត្រូវចាំចំណុចនេះ ពីព្រោះជានិច្ចកាលវាមានការលំបាកបន្តិចនៅពេលចាប់ផ្តើមលេងដំបូងនៅក្នុងក្រុមថ្មី ជាពិសេសបើសិនជាអ្នកធ្លាប់ទៅនឹងការលេងម្នាក់ឯង។

## ៣. អ្នកលេងនៅក្នុងក្រុមបង្រៀន-គ្រូបង្រៀន និងអ្នកសម្របសម្រួលភាសា ៤៥ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូច ការកត់ត្រា និងការបង្ហាញ

**ការរៀបចំ និងសម្ភារៈ:** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត

**គោលបំណង:** ដើម្បីឱ្យគ្រូបង្រៀន និងអ្នកសម្របសម្រួលភាសាឱ្យតម្លៃគ្នា ឱ្យយល់ពីកំលាំងដែលភាគីនីមួយៗនាំមកសម្រាប់ ភាពដៃគូក្នុងក្រុមបង្រៀន។

គ្រូឧទ្ទេសនិយាយថាអ្នកលេងនៅក្នុងក្រុមមានសមត្ថភាព និងបំនិនផ្សេងៗគ្នា ភាពខ្លាំងផ្សេងៗគ្នា។ គ្រូឧទ្ទេសរៀបចំក្រុមតូចដោយមានក្រុមបង្រៀនចំនួនបី (៦នាក់ គ្រូបង្រៀន និងអ្នកសម្របសម្រួលភាសា) នាក់នៅក្នុងក្រុមនីមួយៗ។ គ្រូឧទ្ទេសប្រាប់សិក្ខាកាមៈ *ចូរគិតអំពីក្រុមបង្រៀនដែលអ្នកនឹងទៅធ្វើការនៅក្នុងថ្នាក់ទី១-តើអ្នកគិតថាគ្រូបង្រៀននឹងនាំមកនូវចំណុចខ្លាំងអ្វីខ្លះ និងអ្នកសម្របសម្រួលភាសានឹងនាំមកនូវចំណុចខ្លាំងអ្វីខ្លះដែរ? ចូរសរសេរគំនិតរបស់អ្នកនៅក្នុងតារាងដែលមានពីកូឡោន-កូឡោនមួយសម្រាប់គ្រូបង្រៀន និងមួយទៀតសម្រាប់អ្នកសម្របសម្រួលភាសា (មើលខាងក្រោម)។*

គ្រូឧទ្ទេសនឹងឃើញថាសិក្ខាកាមមិនអាចសរសេរបានគំនិតច្រើនទេ អំពីចំណុចខ្លាំងរបស់អ្នកសម្របសម្រួលភាសា។ គ្រូឧទ្ទេសអាចប្រើសំនួរដើម្បីរំលឹកពួកគាត់អំពីខ្លឹមសារមួយចំនួនដែលមាននៅក្នុងថ្ងៃទី១ និងថ្ងៃទី២អំពីការសិក្សារបស់កុមារនៅផ្ទះ។

| គ្រូបង្រៀន | អ្នកសម្របសម្រួលភាសា |
|---|---|
| *ដឹងអំពីការបង្រៀនកុមារនៅសាលារៀន* | *ដឹងអំពីភាសាកំណើតរបស់កុមារ និងភាសាខ្មែរ* |
| *ដឹងអំពីការងាររដ្ឋបាលរបស់គ្រូបង្រៀន* | *ស្គាល់កុមារ និងគ្រួសាររបស់ពួកគេបានច្បាស់* |
| *ដឹងអំពីមុខវិជ្ជាដែលត្រូវបង្រៀន សៀវភៅសិស្ស និងគ្រូ* | *ស្គាល់ពីវប្បធម៌របស់កុមារបានច្បាស់* |
| *ដឹងពីរបៀបធ្វើផែនការ និងការបង្រៀន* | *ដឹងអ្វីដែលកុមារបានចេះដឹងរួចហើយនៅពេលពួកគេមកសាលា* |
| *ដឹងពីការបង្កើតតេស្ត និងការកែ ដាក់ពិន្ទុ* | *ដឹងពីកម្រិតសមត្ថភាពពិតប្រាកដរបស់កុមារក្នុងភាសាខ្មែរ* |
| *មានចំណេះដឹងច្រើនខាងភាសាខ្មែរ* | *ស្គាល់ពីទំនាក់ទំនងរបស់កុមារជាមួយកុមារផ្សេងទៀត* |
| *មានចំណេះដឹងច្រើនខាងវប្បធម៌ខ្មែរ* | *ងាយធ្វើឱ្យមានភាពស្និទស្នាលជាមួយកុមារ ពីព្រោះពួកគាត់មិនមែនជាគ្រូបង្រៀន* |
| *។ល។* | *។ល។* |

នៅពេលក្រុមទាំងឡាយបានបញ្ចប់ គ្រូឧទ្ទេសប្រាប់ក្រុមនីមួយៗឱ្យបិទក្រដាសធំរបស់ពួកគាត់នៅលើក្តារខៀន ហើយឱ្យសមាជិកម្នាក់ក្នុងក្រុមឡើងបង្ហាញពីគំនិត។ ចូរប្រមូលគំនិតល្អៗទាំងអស់ ហើយសរសេរចូលទៅក្នុងតារាង។

## សម្រាកពេលព្រឹក

## ៤.ការយល់ដឹង និងការគោរពភាពខុសគ្នាខាងវប្បធម៌ ៣០ នាទី

**សកម្មភាពចម្បង:** ការពិភាក្សា និង ការរិះគិតថ្មី

**ការរៀបចំ និងសម្ភារ:** ក្រដាសវ៉ាមធំ ហ្វឺត ស្កុត

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការស្វែងយល់ និងការគោរពភាពខុសគ្នាខាងវប្បធម៌ និងផ្តល់គំនិតរបស់ ពួកគាត់អំពីចំណុចនេះ ។

គ្រូឧទ្ទេសនិយាយថាសិក្ខាកាមបានរកឃើញនៅក្នុងដំណាក់កាលបង្រៀនចុងក្រោយ អំពីចំណុចខ្លាំងបំផុតមួយក្នុងចំណោមចំណុចខ្លាំងផ្សេងទៀត ដែលអ្នកសម្របសម្រួលភាសានាំមកនៅក្នុងក្រុមបង្រៀនគឺចំណេះដឹងខាងភាសា និងវប្បធម៌របស់កុមារ ។ នេះមានន័យថាក្រុមបង្រៀនមានចំណុចខ្លាំងពីព្រោះក្រុមនេះមានសមាជិកដែលមានចំណេះដឹងអំពី ភាសាខ្មែរ និងវប្បធម៌ និង ភាសាកំណើតរបស់កុមារនិងវប្បធម៌ ។

គ្រូឧទ្ទេសសួរៈ *តើហេតុអ្វីបានជាអ្នកគិតថាវាជាការសំខាន់សម្រាប់អ្នករាល់គ្នាត្រូវមានការស្វែងយល់និងការគោរពចំពោះភាសានិងវប្បធម៌ខុសគ្នារបស់មនុស្សដែលរស់នៅក្នុងប្រទេសដូចគ្នា?*

គ្រូឧទ្ទេសប្រាប់សិក្ខាកាមទាំងឡាយឱ្យផ្តល់គំនិតរបស់ពួកគាត់ ហើយគ្រូឧទ្ទេសម្នាក់ទៀតសរសេរគំនិតនោះនៅលើក្តារខៀន ឬលើក្រដាសផ្ទាំងធំ ។

ចម្លើយរំពឹងទុក

- *ដើម្បីឱ្យមនុស្សអាចរស់នៅជាមួយគ្នាដោយសន្តិភាព*
- *ដើម្បីឱ្យមនុស្សដែលមកពីវប្បធម៌មួយធ្វើអ្វីៗកុំឱ្យប៉ះពាល់ដល់មនុស្សដែលមកពីវប្បធម៌ផ្សេងទៀត*
- *ដើម្បីឱ្យមនុស្សដែលមកពីវប្បធម៌ជនជាតិមិនត្រូវបានគេរើសអើង*
- *វប្បធម៌ និងភាសាគឺជាផ្នែកមួយនៃអត្តសញ្ញាណរបស់មនុស្សម្នាក់ ហើយការដែលមិនបានបង្ហាញការគោរពឬការយល់ដឹងអាចបំផ្លាញនូវទំនុកចិត្ត និងការគោរពគ្នាដែលអាចនាំឱ្យមានបញ្ហាផ្សេងៗទៀត ។*
- *វាជាផ្នែកមួយរបស់មនុស្សចេះដឹងដែលត្រូវស្គាល់អ្នកជិតខាង/ប្រជាពលរដ្ឋជិតខាង*
- *ពីព្រោះវាគឺជាច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេស*
- *ពីព្រោះវាជាច្បាប់របស់អន្តរជាតិ*

- ។ល។

គ្រូឧទ្ទេសនិយាយថាមានឧទាហរណ៍ជាច្រើនពីប្រវត្តិសាស្ត្រ និងពីប្រទេសដទៃទៀតនៅក្នុងពិភពលោកនូវព្រឹត្តិការណ៍ដែលគួរឱ្យខ្លាចដោយសារការមិនយល់ និងការមិនគោរពគ្នានៃភាពខុសគ្នាខាងវប្បធម៌។ នេះគឺជាមូលហេតុដែលនាំឱ្យមានសង្គ្រាមស៊ីវិលជាច្រើន ដែលនាំឱ្យខាតបង់អាយុជីវិត និងសុភមង្គលយ៉ាងច្រើនសម្រាប់មនុស្សនៅលើពិភពលោក។ វាជាមូលហេតុដែលរដ្ឋាភិបាលនៅក្នុងពិភពលោក និងប្រព័ន្ធអប់រំជាច្រើនមានគោលនយោបាយឱ្យមានពហុវប្បធម៌ និងលើកទឹកចិត្តឱ្យសមាជិកនៃក្រុមភាសាទាំងអស់ដែលរស់នៅក្នុងប្រទេសមួយឱ្យមានការចូលរួមក្នុងគ្រប់ផ្នែកទាំងអស់របស់សង្គម បូករួមទាំងការអប់រំ។

ជាឧទាហរណ៍ រដ្ឋាភិបាលកម្ពុជានៅពេលបច្ចុប្បន្នបានជំរុញយ៉ាងសកម្មឱ្យមានការចូលរួមរបស់កុមារពីសហគមន៍ជនជាតិនៅក្នុងការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ មានកន្លែងជាច្រើនបម្រុងទុកសម្រាប់ពួកគេនៅក្នុងមជ្ឈមណ្ឌលគរុកោសល្យខេត្ត ដើម្បីឱ្យគ្រូមកពីភូមិ ឃុំ និងស្រុកកជនជាតិឬខ្មែរ-ឥស្លាមឱ្យច្រើន។ ក្រសួងអប់រំ យុវជន និងកីឡាយល់ឃើញថា គ្រូជនជាតិ ឬគ្រូខ្មែរ-ឥស្លាម គឺជាមធ្យោបាយមួយដ៏ល្អដើម្បីជួយកុមារទាំងអស់ឱ្យទទួលបានការអប់រំពាក់ព័ន្ធនឹងអត្តសញ្ញាណវប្បធម៌ និងអាចរស់នៅ និងធ្វើការដោយងាយស្រួលជាពលរដ្ឋកម្ពុជា។

## ៥. ការទំនាក់ទំនងពហុវប្បធម៌ និងការសិក្សាពីគ្នាទៅវិញទៅមក ៤៥ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស

**ការរៀបចំ និងសម្ភារៈ:** ផែនការរបស់គ្រូឧទ្ទេស

**គោលបំណង:** ដើម្បីឱ្យសិក្ខាកាមដឹងថាភាពខុសគ្នាខាងវប្បធម៌ ជួនកាលអាចនាំឱ្យមានការលំបាកក្នុងការទំនាក់ទំនងឱ្យបាន ច្បាស់លាស់ ជួនកាលការយល់ខុសអាចកើតមានឡើងដោយសារភាពខុសគ្នាខាងវប្បធម៌ គឺមិនមែនដោយសារការខ្ជិលច្រអូស ការនិយាយកុហក ឬអកប្បកិរិយាអវិជ្ជមានណាមួយឡើយ។

គ្រូឧទ្ទេសនិយាយថាការខិតខំប្រឹងប្រែងមួយក្នុងចំណោមការខិតខំផ្សេងទៀត ក្នុងការងារបង្រៀនជាក្រុមរវាងគ្រូបង្រៀន និងអ្នកសម្របសម្រួលភាសាគឺ "ការទំនាក់ទំនងពហុវប្បធម៌"។ នេះមានន័យថាមនុស្សដែលមកពីវប្បធម៌មួយនិយាយអ្វីមួយប្រកបដោយអត្ថន័យ និងគោលបំណងច្បាស់លាស់ តែមនុស្សម្នាក់ទៀតដែលមកពីវប្បធម៌ផ្សេងឆ្លើយតបតាមរបៀបដែលពួកគេមិនរំពឹងទុក។ ជាញឹកញាប់គេចាត់ទុកបញ្ហានេះជាហេតុផលល្អមួយដោយផ្អែកលើភាពខុសគ្នាខាងវប្បធម៌។ ប៉ុន្តែជួនកាលមនុស្សដែលនៅក្នុងស្ថានភាពនេះគិតថាមានហេតុផលមួយចំនួនផ្សេងទៀត ដែលពួកគេទទួលបានចម្លើយដោយមិនរំពឹងទុកបែបនេះ។ ពួកគេអាចគិតថាមនុស្សដែលនិយាយនោះល្ងីល្ងើឬខ្ជិល នៅពេលដែលគេរំពឹងចង់បានការពន្យល់ដ៏ល្អមួយ។

គ្រូឧទ្ទេសនិយាយប្រាប់សិក្ខាកាមនូវរឿងមួយៈ រឿងនេះជាឧទាហរណ៍មួយដែលអាចផ្តល់គំនិតដល់សិក្ខាកាម។ រឿងនេះបានមកពីប្រទេសអូស្ត្រាលី។ មានមនុស្សពីរនាក់ ម្នាក់មកពីរតំបន់ត្រូពិចខាងជើងដែលជាតំបន់សំបូរព្រៃ ហើយម្នាក់ទៀតមកពីអូស្ត្រាលីកណ្តាលដែលជាតំបន់វាលខ្សាច់បានយល់ព្រមជួបជុំគ្នាដើម្បីទៅប្រមូលទឹកឃ្មុំ។ នៅពេលពួកគេជួបគ្នានៅក្នុងថ្ងៃបន្ទាប់នោះ ម្នាក់កាន់ពូថៅ និងម្នាក់ទៀតកាន់ចំរឹងដែកស្រួច។ ពួកគេទាំងពីរក្រលេកមើលគ្នាទៅវិញទៅមកហើយគិតថា "អ្នកឯងពិតជាល្ងង់ដែលគិតថាប្រមូលទឹកឃ្មុំបានដោយប្រើឧបករណ៍នោះ"។ ប៉ុន្តែនៅពេលពួកគេអង្គុយចុះហើយពិភាក្សាគ្នា ពួកគេបានយល់ច្បាស់អំពីឧបករណ៍នីមួយៗ។

| យកទឹកឃ្មុំពីក្នុងដើមឈើ | យកទឹកឃ្មុំពីក្នុងដីរឹងនៅតំបន់វាលខ្សាច់ |
|---|---|
| | |
| ដោយប្រើពូថៅ | ដោយប្រើដែកគាស់ (ឃ្នាស់) |

គ្រូឧទ្ទេសនិយាយបន្តទៀតៈ នៅក្នុងតំបន់ត្រូពិចខាងជើងនៃប្រទេសអូស្ត្រាលីសត្វឃ្មុំផលិតទឹកឃ្មុំនៅក្នុងសំបុកក្នុងដើមឈើ។ មនុស្សត្រូវតែកាប់ដើមឈើរំលំដោយប្រើពូថៅដើម្បីយកទឹកឃ្មុំនោះ។ ចំណែកនៅភាគកណ្តាលប្រទេសអូស្ត្រាលីពុំមានសត្វឃ្មុំទេ។ មនុស្សយកទឹកឃ្មុំពីសត្វស្រមោច។ សត្វស្រមោចទាំងឡាយមានថង់កំប៉ោងនៅជាប់នឹងដងខ្លួនដែលពេញទៅដោយទឹកឃ្មុំសម្រាប់ចិញ្ចឹមកូន។ សំបុកស្រមោចស្ថិតនៅក្នុងដីស្ងួត រឹង ដូច្នេះមនុស្សត្រូវការដែកចំរឹងរឹង ដើម្បីជីករន្ធនោះ រួចហើយផ្តាច់ថង់ទឹកឃ្មុំនោះពីសត្វស្រមោចនីមួយៗ។

ការយល់ខុសទាំងអស់នេះ អាចកើតមាននៅក្នុងការបង្រៀនជាក្រុម ប៉ុន្តែវាអាចកើតឡើងច្រើនជាងនេះទៅទៀត នៅពេលមានសមាជិកក្រុមបង្រៀនមកពីវប្បធម៌ផ្សេងគ្នា។ លក្ខណៈនេះដោយសារមនុស្សដែលមកពីវប្បធម៌ខុសគ្នាមានការគិតមិនដូចគ្នា...

ពួកគេរៀបចំគ្រួសារ និងជីវភាពរស់នៅក្នុងសង្គមតាមរបៀបខុសគ្នា

ពួកគេមានអាទិភាពនិងតម្លៃផ្សេងៗគ្នា

ពួកគេគិត និងធ្វើចំណាត់ថ្នាក់ទៅលើវត្ថុនៅក្នុងពិភពលោកតាមរបៀបផ្សេងគ្នា

ពួកគេមានពិធី ប្រពៃណី ទំនៀមទម្លាប់ និងអកប្បកិរិយាខុសៗគ្នា

## សម្រាកអាហារថ្ងៃត្រង់

## ៦. ការធ្វើការជាមួយកុមារថ្នាក់ទីមួយ ៧៥ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូចនិង ការធ្វើចំណាត់ថ្នាក់អំពីតួនាទី

**ការរៀបចំ និងសម្ភារ:** ចំណិតប្រយោគ តារាងចំណាត់ថ្នាក់

**គោលបំណង:** សកម្មភាពនេះមានគោលបំណងឱ្យសិក្ខាកាមចូលរួមពិភាក្សាអំពីតួនាទីសមាជិកនៃក្រុមបង្រៀនដោយផ្តល់ឱ្យពួកគេ នូវគំនិតដើម្បីពិភាក្សា និងធ្វើចំណាត់ថ្នាក់ ។ នេះគឺជាសកម្មភាពសំខាន់ ពីព្រោះវានឹងផ្តល់គោលការណ៍អំពីតួនាទីរបស់គ្រូបង្រៀននិងអ្នកសម្របសម្រួលភាសាក្នុងការបង្រៀនជាក្រុម ដែលអ្នកគ្រប់គ្នាក្នុងសិក្ខាសាលាយល់ព្រម ។ (តួនាទីនេះនឹងត្រូវពិភាក្សាម្តងទៀតនៅក្នុងសិក្ខាសាលាសម្រាប់អ្នកសម្របសម្រួលភាសា និងគ្រូបង្រៀននៅចុងឆ្នាំសិក្សា) ។

គ្រូឧទ្ទេសនិយាយថាឥឡូវនេះសិក្ខាកាមគួរតែចាប់ផ្តើមគិតអំពីរបៀបដែលពួកគេធ្វើការជាមួយគ្នាក្នុងការបង្រៀនជាក្រុម ។ គ្រូឧទ្ទេសសួរសិក្ខាកាម *តើតួនាទីសំខាន់ៗរបស់គ្រូបង្រៀនគួរតែធ្វើអ្វីខ្លះ? តើតួនាទីសំខាន់ៗរបស់អ្នកសម្របសម្រួលភាសាគួរតែធ្វើអ្វីខ្លះ?*

គ្រូឧទ្ទេសនិយាយថាដើម្បីជួយសិក្ខាកាមឱ្យគិតអំពីសំនួរនេះ ក្រុមបង្រៀនក្នុងសិក្ខាសាលាបានរៀបចំប្រយោគមួយឈុតដាក់លើចំណិតក្រដាសស្តីអំពីការងារដែលត្រូវធ្វើនៅក្នុងថ្នាក់រៀន ។ កិច្ចការរបស់សិក្ខាកាមគឺត្រូវធ្វើការរួមគ្នាជាក្រុមតូចៗ (៦នាក់-៣ក្រុមបង្រៀន)ដើម្បីអានចំណិតប្រយោគនីមួយៗ ហើយគិតថាវាជាការងាររបស់គ្រូបង្រៀន របស់អ្នកសម្របសម្រួលភាសា ឬជាអ្វីដែលគ្រូបង្រៀន និងអ្នកសម្របសម្រួលភាសាអាចធ្វើរួមគ្នាបាន ។ ពួកគាត់គួរតែបិទប្រយោគនៅខាងក្រោមកូឡោន លើតារាងឱ្យបានសមស្រប ឬបើសិនជាពួកគាត់គិតថាជាកិច្ចការដែលអាចធ្វើរួមគ្នាត្រូវបិទនៅចំបន្ទាត់កណ្តាលដើម្បីឱ្យចុងសន្លឹកប្រយោគស្ថិតនៅក្នុងកូឡោនទាំងពីរ ។ *(ចូរមើលឧទាហរណ៍ខាងក្រោម...)*

| តួនាទីគ្រូបង្រៀន | តួនាទីអ្នកសម្របសម្រួលភាសា |
|---|---|
| *រៀបចំផែនការបង្រៀនដោយប្រើសៀវភៅសិស្ស សៀវភៅគ្រូ* | *ធ្វើការជាមួយកុមារនីមួយៗដែលមិនយល់ភាសាខ្មែរបានល្អ* |
| *ធ្វើតេស្តប្រចាំខែ និងដាក់ពិន្ទុ* | *ជួយពន្យល់សេចក្តីណែនាំរបស់គ្រូទៅសិស្សដែលយល់មិនបានល្អ* |
| *កត់ត្រាវត្តមាន* | |
| *ប្រាប់សិស្សក្នុងថ្នាក់ទាំងមូលអំពីអ្វីដែលត្រូវធ្វើក្នុងមេរៀននីមួយៗ* | |
| *ធ្វើការជាមួយក្រុមកុមារតូចៗ* | |
| *ត្រួតពិនិត្យនិងថែរក្សាកុមារកំពុងធ្វើសកម្មភាពនៅក្រៅថ្នាក់* | |

| | |
|---|---|
| *សរសេរសំបុត្រទៅឪពុកម្ដាយសិស្សក្នុងសៀវភៅទំនាក់ទំនង* | |
| *ស្វាគមន៍កុមារដែលមកសាលារៀននៅពេលព្រឹក* | |
| *ពិនិត្យសុខភាព* | |
| *ត្រួតពិនិត្យសកម្មភាពកីឡា* | |
| *ត្រួតពិនិត្យមេរៀននៅបណ្ណាល័យ* | |
| *សង្កេតកុមារ និងពិភាក្សាពីដំណើរការក្នុងការបង្រៀនជាក្រុម* | |
| *ត្រួតពិនិត្យការងារក្នុងក្រុមសិក្សាតូច* | |
| *សំអាតក្ដារខៀន សំអាតបន្ទប់រៀន ចាក់សោទ្វារ** | |
| | |
| | |

* យើងត្រូវដឹងថាអ្នកសម្របសម្រួលភាសា**មិនមែន**ជាអ្នកដែលគ្រូបង្រៀនត្រូវប្រគល់រាល់ការងារមិនល្អទាំងឡាយឱ្យធ្វើទេ។ បើសិនជាមានករណីបែបនេះវាអាចជាព័ត៌មានមួយមិនល្អទៅដល់មនុស្សគ្រប់គ្នា។ ដូច្នេះវាមិនមែនជាការងារក្រុមដ៏ល្អនោះទេ។

ក្រុមតូចចូលរួមធ្វើចំណាត់ថ្នាក់ជាមួយក្រុមដទៃ ហើយសិក្ខាកាមទាំងអស់គួរតែព្យាយាមស្វែងរកការយល់ព្រមគ្នាអំពីការងារនីមួយៗក្នុងការពិភាក្សា។

គ្រូឧទ្ទេសនិយាយថា ដោយសារគំនិតនៃការបង្រៀនជាក្រុមរវាងគ្រូនិងអ្នកសម្របសម្រួលភាសាជាគំនិតថ្មី ពុំមានគោលនយោបាយនៅឡើយ ហើយក៏ពុំមានចម្លើយត្រឹមត្រូវចំពោះសំនួរទាំងនេះផងដែរ។ ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយគឺថាការសាកល្បងឱ្យមានអ្នកសម្របសម្រួលភាសាដែលយើងទាំងអស់គ្នាកំពុងចូលរួមនេះ ចំណុចសំខាន់គឺវានឹងជួយផ្ដល់បទពិសោធន៍ឱ្យអេស្កាប់អំពីរបៀបនៃការបង្រៀនជាក្រុមដោយមានដំណើរការល្អ ហើយអាចផ្ដល់ទៅក្រសួងអប់រំ យុវជន និងកីឡា។ បុគ្គលិកអេស្កាប់នឹងតាមដានការបង្រៀនជាក្រុមនៅក្នុងអំឡុងពីរបីខែចុងក្រោយនៃឆ្នាំសិក្សានេះដើម្បីប្រមូលគំនិត បទពិសោធន៍ពីសិក្ខាកាម។ អេស្កាប់នឹងរៀបចំសិក្ខាសាលាមួយផ្សេងទៀតក្នុងវិស្សមកាលឆ្នាំសិក្សានេះសម្រាប់សិក្ខាកាមទាំងអស់មានឱកាសជួបគ្នា និងចែករំលែកបទពិសោធន៍។

## ៧. កុមារដែលអាចទទួលផលប្រយោជន៍ពីការជួយរបស់អ្នកសម្របសម្រួលភាសា ៦០ នាទី

**សកម្មភាពចម្បង:** ការពិភាក្សាក្រុមតូចអំពីរបៀបដែលអ្នកសម្របសម្រួលភាសាអាចជួយកុមារបាន (ករណីសិក្សា)

**ការរៀបចំ និងសម្ភារៈ:** ឯកសារផ្ដល់ជាគំនិតដែលយកពីដំណាក់កាលបង្រៀនទី៦ ថ្ងៃទី២

**គោលបំណង:** ដើម្បីឱ្យមានការយល់ស្របគ្នារវាងអ្នកសម្របសម្រួលភាសា និងគ្រូបង្រៀនអំពីតួនាទីរបស់អ្នកសម្រប-

សម្រួលភាសានៅក្នុងថ្នាក់ និងឯកសារដែលផ្តល់គំនិតជាក់លាក់មួយចំនួនអំពីរបៀបដែលពួកគាត់អាចជួយគ្រូបង្រៀន។

គ្រូឧទ្ទេសចាប់ផ្តើមពន្យល់ និងផ្តល់សេចក្តីណែនាំជាភាសាអង់គ្លេស (ឬភាសាផ្សេងទៀតដែលសិក្ខាកាមមិនយល់)។ គ្រូឧទ្ទេសបង្ហាញអារម្មណ៍ថាមានការរំខាន នៅពេលសិក្ខាកាមមិនធ្វើតាមអ្វីដែលគាត់កំពុងនិយាយ។ បន្ទាប់មកគ្រូឧទ្ទេសម្នាក់ទៀតពន្យល់ថានេះគឺជាការសំដែងតួ និងជាគំនិតដែលដាក់សិក្ខាកាមទៅក្នុងស្ថានភាពមួយ ដែលមិនបានដឹងថាមានអ្វីបានកើតឡើង។

គ្រូឧទ្ទេសនិយាយថាៈ អ្នកគ្រប់គ្នាដឹងពីហេតុផលដែលនាំឱ្យមានអ្នកសម្របសម្រួលភាសាធ្វើការនៅក្នុងថ្នាក់រៀនជាមួយគ្រូបង្រៀនគឺ (១) ដើម្បីបង្កើតបរិយាកាសស្និទស្នាល និងងាយស្រួលសម្រាប់កុមារដែលមិនចេះនិយាយភាសាខ្មែរពីកំណើត។ និង (២) ដើម្បីជួយកុមារទាំងនេះឱ្យរៀនសូត្រកាន់តែប្រសើរឡើង។

គ្រូឧទ្ទេសនិយាយថាៈ ប៉ុន្តែកុមារមួយចំនួនដែលមកពីគ្រួសារនិយាយភាសាចាមធ្វើកិច្ចការបានល្អនៅសាលារៀន និងកុមារមួយចំនួនមកពីគ្រួសារនិយាយភាសាខ្មែរបែរជាមានការលំបាកក្នុងការធ្វើកិច្ចការនៅសាលារៀនទៅវិញ។ កាលពីម្សិលមិញអ្នកសម្របសម្រួលភាសាបានគិតអំពីស្ថានភាពប្រភេទផ្សេងៗនៃកុមារនៅក្នុងថ្នាក់រៀន និងពិភាក្សាអំពីរបៀបដែលពួកគេអាចជួយ។

បន្ទាប់មកគ្រូឧទ្ទេសសួរអ្នកសម្របសម្រួលភាសាម្នាក់ឬពីរនាក់ឱ្យពណ៌នាអំពីសកម្មភាព នៅក្នុងដំណាក់កាលបង្រៀនទី៦ ថ្ងៃទី២ និងបង្ហាញពួកគាត់អំពីតារាងគំនិតក្នុងការធ្វើការជាមួយប្រភេទកុមារខុសៗគ្នានៅក្នុងថ្នាក់រៀន។

នៅពេលចប់ការបង្ហាញ អ្នកសម្របសម្រួលភាសា និងគ្រូបង្រៀនបង្កើតជាក្រុមតូចដើម្បីពិភាក្សាលទ្ធផលនៅថ្ងៃទី២។ គ្រូបង្រៀនក៏អាចផ្តល់ជាគំនិតល្អដែលអ្នកសម្របសម្រួលភាសាអាចជួយកុមារ និងជួយពួកគាត់ក្នុងការគ្រប់គ្រងថ្នាក់រៀន។ សមាជិកម្នាក់នៅក្នុងក្រុមអាចកត់ត្រានូវគំនិតសំខាន់ៗទាំងនោះ (គ្រូឧទ្ទេសគួរតែជាអ្នកកត់ត្រា)។

បន្ទាប់ពីការពិភាក្សា អ្នកតំណាងគ្រូបង្រៀនពីក្រុមនីមួយៗគួរតែបង្ហាញពីគំនិតរបស់ពួកគាត់។ គ្រូឧទ្ទេសអាចជួយសម្របសម្រួលការពិភាក្សាដើម្បីបញ្ជាក់ឱ្យច្បាស់ពីគំនិតរបស់គ្រូបង្រៀន និងដើម្បីសរុបរួមជាគំនិតសំខាន់។

នៅពេលបញ្ចប់ដំណាក់កាលបង្រៀនគ្រូឧទ្ទេសធ្វើការសង្ខេបឡើងវិញ។

**ចប់ថ្ងៃទី៣**

## ថ្ងៃទី៤: អ្នកសម្របសម្រួលភាសា អេស្តាប់ និងសមាគមយុវជនឥស្លាមកម្ពុជា

**១. តើអ្វីខ្លះដែលធ្វើឱ្យកុមារសប្បាយចិត្តមកសាលារៀន? បញ្ញត្តិអំពីបរិស្ថានសិក្សាកុមារមេត្រី ៦០ នាទី**

***សកម្មភាពចម្បង:*** ការពិភាក្សា ការរិះគិតថ្មី និងការបង្ហាញខ្លីៗ

***ការរៀបចំ និងសម្ភារៈ:*** ប័ណ្ណ និងហ្វឺត ស្កុត តារាងសង្ខេបបញ្ញត្តិសាលាកុមារមេត្រី

***គោលបំណង:*** សកម្មភាពនេះជួយឱ្យសិក្ខាកាមចាប់ផ្ដើមគិតអំពីអ្វីដែលធ្វើឱ្យសាលារៀនជាកន្លែង "កុមារមេត្រី" និងបង្ហាញពួកគាត់អំពីបញ្ញត្តិ "សាលាកុមារមេត្រី"។

គ្រូឧទ្ទេសនិយាយថាសិក្ខាកាមទើបតែមើលឃើញភាពខុសគ្នាជាច្រើនរវាងការសិក្សានៅផ្ទះ និងការសិក្សានៅសាលារៀន។ សម្រាប់កុមារភាគច្រើន សាលារៀនគឺជាកន្លែងដែលគួឱ្យខ្លាច ពីព្រោះវាមានលក្ខណៈខុសប្លែកពីបរិស្ថានដែលពួកគេបានចំណាយពេល៦ឆ្នាំដំបូងនៃជីវិតរស់នៅរបស់ពួកគេ។ ការខិតខំប្រឹងប្រែងធំបំផុតមួយសម្រាប់សាលារៀនគឺត្រូវធ្វើឱ្យកុមារមានអារម្មណ៍សប្បាយរីករាយក្នុងការរស់នៅ និងដើម្បីឱ្យពួកគេរីករាយក្នុងការរៀនសូត្រផងដែរ។

គ្រូឧទ្ទេសសួរសិក្ខាកាម: តើសាលារៀន និងគ្រូបង្រៀនអាចធ្វើអ្វីខ្លះដើម្បីឱ្យកុមារមានអារម្មណ៍សប្បាយរីករាយមករៀននៅសាលារៀន? ក្នុងពេលសិក្ខាកាមផ្ដល់គំនិតរបស់ពួកគាត់ចំពោះសំនួរនេះ គ្រូឧទ្ទេស (និង ឬសិក្ខាកាម) សរសេរគំនិតដាក់លើប័ណ្ណ។ គ្រូឧទ្ទេសអាចប្រើសំនួរដើម្បីជួយសិក្ខាកាមឱ្យគិតអំពីអ្វីៗដូចជា សុខភាព និងសុវត្ថិភាព ការគ្រប់គ្រងសាលារៀន ។ល។ គ្រូឧទ្ទេសព្យាយាមធ្វើឱ្យសិក្ខាកាមគិតអំពីចំណុចនៅក្នុងផ្នែកទាំង៥នៅក្នុងសាលាកុមារមេត្រី។ គ្រូឧទ្ទេសបិទប័ណ្ណទាំងនោះនៅលើក្ដារខៀនក្នុងខណៈពេលសិក្ខាកាមកំពុងធ្វើការ។

នៅពេលសិក្ខាកាមបានបញ្ចប់ការងារ គ្រូឧទ្ទេសបិទ**តារាងសាលាកុមារមេត្រី** ដែលបង្ហាញផ្នែកទាំង៥។ គ្រូឧទ្ទេសនិយាយថា ក្រសួងអប់រំ យុវជន និងកីឡាមាននយោបាយមួយឈ្មោះថា "សាលាកុមារមេត្រី" ដែលមានគោលបំណងធ្វើឱ្យសាលារៀនជាកន្លែងសប្បាយរីករាយសម្រាប់កុមារមករៀន និងដែលធ្វើឱ្យការសិក្សាមានការចាប់អារម្មណ៍ និងគួរឱ្យសប្បាយ។ គ្រូឧទ្ទេសពន្យល់អំពីផ្នែកសំខាន់ៗទាំង៥របស់សាលាកុមារមេត្រី។ បន្ទាប់មកគ្រូឧទ្ទេសប្រាប់ឱ្យសិក្ខាកាមព្យាយាមធ្វើចំណាត់ថ្នាក់ប័ណ្ណគំនិតរបស់ពួកគាត់នៅខាងក្រោមផ្នែក (មួយឬច្រើន) ទាំង៥នៃសាលាកុមារមេត្រី។

សន្និដ្ឋានៈ គ្រូឧទ្ទេសនិយាយថា អេស្កាប់គិតថាអ្នកសម្របសម្រួលភាសាមានសារៈសំខាន់ណាស់ក្នុងការជួយសាលារៀនឱ្យមានលក្ខណៈកុមារមេត្រីច្រើនឡើងសម្រាប់កុមារដែលមិនចេះនិយាយភាសាខ្មែរបានល្អ។ អ្នកសម្របសម្រួលភាសាអាចសម្រេចគោលបំណងនេះដោយការជួយកុមារ និងដោយការជួយគ្រូបង្រៀន។ របៀប ឬមធ្យោបាយដែលពួកគាត់អាចជួយកុមារ និងគ្រូបង្រៀនគឺនៅក្នុងប្រធានបទព្រឹកនេះ ប៉ុន្តែជាដំបូងយើងនឹងគិត និងពិភាក្សាអំពីរបៀបដែលគ្រូបង្រៀនរៀបចំចាត់ចែងថ្នាក់រៀន។

*កំណត់សំគាល់: កាលពីមុនក្រសួងអប់រំយុវជន និងកីឡា ប្រើប្រាស់បញ្ញត្តិសាលាកុមារមេត្រីដែលមាន ៦ Dimensions ប៉ុន្តែចាប់ពីដើមឆ្នាំ២០០៦ក្រសួងបានបញ្ចូល Dimensions ទី៤ (យេនឌ័រ) ទៅក្នុង Dimensions ទី១ (ការអប់រំបញ្ចូលគ្នា)។ ដូចនេះនៅពេលបច្ចុប្បន្នមានតែ ៥ Dimensions ទេ។*

## ២. របៀបដែលអេស្កាប់នឹងជួយអ្នកសម្របសម្រួលភាសា-ប្រាក់ឧបត្ថម្ភ ការបណ្តុះបណ្តាល ការជួយគាំទ្រ ការគ្រប់គ្រងសហគមន៍ ៣០ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស និងមានការសួរ និងឆ្លើយសំនួរ

**ការរៀបចំ និងសម្ភារៈ** ផែនការរបស់គ្រូឧទ្ទេស

**គោលបំណង:** ដើម្បីផ្តល់ព័ត៌មានឱ្យសិក្ខាកាមអំពីសកម្មភាពរបស់អ្នកសម្របសម្រួលភាសា។

គ្រូឧទ្ទេសធ្វើការបង្ហាញមួយទៅឱ្យសិក្ខាកាមអំពីរចនាសម្ព័ន្ធនៃអន្តរាគមន៍អ្នកសម្របសម្រួលភាសា ស្ថិតនៅក្រោមចំណងជើងទាំងបួនខាងក្រោម។ បន្ទាប់ពីការបង្ហាញលើផ្នែកនីមួយៗ គ្រូឧទ្ទេសសួរសិក្ខាកាមថាតើពួកគេមានសំនួរ ឬក៏ការបរិយាយបន្ថែមណាមួយចំពោះការបង្ហាញរបស់គ្រូឧទ្ទេស។

### ការគ្រប់គ្រង

គ្រូឧទ្ទេសនិយាយថាៈ សកម្មភាពរបស់អ្នកសម្របសម្រួលភាសាពីភាសាត្រូវបានគ្រប់គ្រងដោយគណកម្មការកម្រងសាលារៀនមូលដ្ឋាន (LCSC) ដែលជាផ្នែកមួយនៃតួនាទីរបស់ខ្លួនក្នុងការគ្រប់គ្រងសកម្មភាពក្នុងកម្រងដោយប្រើប្រាស់មូលនិធិដែលជាអំណោយសម្រាប់អភិវឌ្ឍន៍កម្រងសាលារៀន។ នៅរាល់ឆ្នាំសម្រាប់រយៈពេលពីឆ្នាំរបស់កម្មវិធីអេស្កាប់ គណកម្មការកម្រងសាលារៀនមូលដ្ឋានបានធ្វើផែនការសម្រាប់ផ្តល់ភាពងាយស្រួល ចូលសាលារៀន និងគុណភាពអប់រំនៅក្នុងសាលារៀនក្នុងកម្រង។ អេស្កាប់ផ្តល់មូលនិធិដែលបានពី USAIDដល់កម្រងសាលារៀនដើម្បីប្រតិបត្តិផែនការរបស់ពួកគេ។ សកម្មភាពអ្នកសម្របសម្រួលភាសាគឺជាផ្នែកមួយនៃផែនការកម្រងសម្រាប់ឆ្នាំសិក្សា២០០៥-២០០៦។ គណកម្មការកម្រងសាលារៀនមូលដ្ឋានអាចនឹងជ្រើសរើសសកម្មភាពនេះម្តងទៀតក្នុងឆ្នាំសិក្សា២០០៦-២០០៧។ ចំពោះគណកម្មការផ្សេងទៀត នៅពេលបានឮពីសកម្មភាពនេះអាចនឹងសម្រេចចិត្តជ្រើសរើសយកសកម្មភាពនេះទៅអនុវត្តផងដែរ។

គ្រូឧទ្ទេសនិយាយថាៈ គណកម្មការកម្រងសាលារៀនមូលដ្ឋាននឹងត្រួតពិនិត្យតាមដានការងាររបស់អ្នកសម្របសម្រួលភាសាដែលកំពុងបម្រើការ និងជាអ្នកទទួលខុសត្រូវលើសកម្មភាពផ្សេងៗទៀត ដូចជានៅពេលមានបញ្ហា និងការអនុវត្តការងារមិនត្រូវគ្នាជាមួយគ្រូបង្រៀន។

**ប្រាក់ឧបត្ថម្ភ**

គ្រូឧទ្ទេសនិយាយថាៈ ប្រាក់ឧបត្ថម្ភចំនួន១៥ ដុល្លាសម្រាប់អ្នកសម្របសម្រួលភាសាគឺត្រូវបានបើកដោយគណកម្មការកម្រងសាលារៀនមូលដ្ឋាន។ ប្រាក់ឧបត្ថម្ភត្រូវបានផ្តល់សម្រាប់ការងារជាក់ស្តែង មានន័យថាប្រាក់ឧបត្ថម្ភនឹងត្រូវបានផ្តល់សម្រាប់តែនរណាមួយដែលមានឈ្មោះជាអ្នកសម្របសម្រួលភាសា។ បើសិនជាអ្នកសម្របសម្រួលភាសាអវត្តមានពីការងារដោយគ្មានហេតុផលត្រឹមត្រូវ (ឧ. មានជំងឺ សុំច្បាប់ចូលរួមពិធីបុណ្យគ្រួសារ) នោះនាំឱ្យមានការកាត់បន្ថយប្រាក់ឧបត្ថម្ភផងដែរ។

គ្រូឧទ្ទេសនិយាយថាៈ ប្រាក់ឧបត្ថម្ភនឹងត្រូវបានបើកនៅចុងខែនីមួយៗសម្រាប់កាបំពេញការងារបានពេញលេញក្នុងមួយខែ។ អេស្កាប់នឹងបើកប្រាក់ខែឱ្យអ្នកសម្របសម្រួលភាសានៅខែឧសភា មិថុនា កក្កដា (សរុបទាំងអស់មាន៣ខែឬ៤៥ដុល្លា)។

**ការត្រួតពិនិត្យតាមដាន និងការពង្រឹងបន្ថែម**

គ្រូឧទ្ទេសនិយាយថាៈ អេស្កាប់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការសាកល្បងកម្មវិធីអ្នកសម្របសម្រួលភាសាពីព្រោះវាជាគំនិតមួយដែលអាចប្រើប្រាស់នៅកន្លែងផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាដែលមានកុមារនិយាយភាសាកំណើត ហើយចេះនិយាយភាសាខ្មែរតិចតួចឬមិនចេះ។ បុគ្គលិកអេស្កាប់នឹងទៅទស្សនកិច្ចសាលារៀនដែលមានអ្នកសម្របសម្រួលភាសាកំពុងបម្រើការ និងពិភាក្សាជាមួយអ្នកសម្របសម្រួលភាសា ក្រុមគ្រូបង្រៀន នាយកសាលារៀន កុមារ និងឪពុកម្តាយស្តីអំពីសកម្មភាពនេះ។

គ្រូឧទ្ទេសនិយាយថាៈ នៅពេលបញ្ចប់ឆ្នាំសិក្សានេះអេស្កាប់នឹងរៀបចំសិក្ខាសាលាវាយតម្លៃមួយសម្រាប់អ្នកសម្របសម្រួលភាសាទាំងអស់ និងក្រុមគ្រូបង្រៀន។ គោលបំណងរបស់សិក្ខាសាលា គឺចង់ស្វែងរកព័ត៌មានលំអិតអំពីបទពិសោធន៍នៃក្រុមអ្នកសម្របសម្រួលភាសាដំបូងគេ។ អេស្កាប់មានចំណាប់អារម្មណ៍ចង់ឃើញមានផលប៉ះពាល់របស់កម្មវិធីអ្នកសម្របសម្រួលភាសាដែលនាំឱ្យមានការចូលរួមរបស់កុមារ និងការសិក្សាកើនឡើង។ ឧទាហរណ៍ តើអ្នកសម្របសម្រួលភាសានៅក្នុងថ្នាក់រៀនបានបង្កើននូវការចូលរួមពីកុមារដែលពីពេលមុនកុមារទាំងនេះមិនមានភាពសកម្មដែរឬទេ? តើដោយសារមានអ្នកសម្របសម្រួលភាសានៅក្នុងថ្នាក់រៀន បានជួយកុមារឱ្យធ្វើកិច្ចការចប់ពេញលេញដែរឬទេ? តើសកម្មភាពនេះបានជួយកុមារដែលរៀនមិនបានពូកែឱ្យរីកចំរើនហើយអាចឡើងថ្នាក់ទីមួយ និងបន្តទៅថ្នាក់ទីពីរបានដែរឬទេ?

## ៣. តួនាទីរបស់សមាគមមនឹយុវជនឥស្លាមកម្ពុជា ជាមិត្តរបស់អេស្កាប់ ៣០ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់សមាគមមន៏យុវជនឥស្លាមកម្ពុជា

**ការរៀបចំ និងសម្ភារ:** ផែនការរបស់សមាគមមន៏យុវជនឥស្លាមកម្ពុជា និងសម្ភារ

**គោលបំណង:** ដើម្បីជំរាបជូនសិក្ខាកាមអំពីសមាគមមន៏យុវជនឥស្លាមកម្ពុជា-សាវតា គោលបំណង ប្រតិប័ត្រការ

សមាគមមន៏យុវជនឥស្លាមកម្ពុជានិយាយប្រាប់អំពីសាវតា គោលបំណង និងប្រតិប័ត្រការនៅពេលបច្ចុប្បន្នរបស់សមាគមមន៏យុវជនឥស្លាមកម្ពុជា។ គាត់អាចនិយាយអំពីអភិបាលកិច្ចនៃអង្គការក្រៅរដ្ឋាភិបាល (គណកម្មការ គណអធិបតី បុគ្គលិក។ល។ គាត់ក៏អាចនិយាយអំពីតួនាទីរបស់សមាគមមន៏យុវជនឥស្លាមកម្ពុជានៅក្នុងកម្មវិធីអេស្កាប់ និងសកម្មភាពរបស់អ្នកសម្របសម្រួលភាសា។

## ៤. មនុស្សដែលអាចជួយអ្នកសម្របសម្រួលភាសានៅពេលមានបញ្ហាកើតឡើង ៣០ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស ការពិភាក្សា និងការរិះគិតថ្មី

**ការរៀបចំ និងសម្ភារ:** ក្រដាសរ៉ាមធំសម្រាប់សរសេរគំនិតរបស់សិក្ខាកាម

**គោលបំណង:** ដើម្បីប្រាប់សិក្ខាកាមអំពីមនុស្សដែលអាចជួយអ្នកសម្របសម្រួលភាសានៅពេលមានបញ្ហាកើតឡើង និងព្រមទាំងប្រមូលផ្តុំគំនិតរបស់សិក្ខាកាមអំពីយុទ្ធសាស្ត្រផ្សេងៗសម្រាប់ដោះស្រាយបញ្ហា។

គ្រូឧទ្ទេសនិយាយថា: អ្នកសម្របសម្រួលភាសាដែលមានបញ្ហាអំពីការងាររបស់ពួកគេអាចនិយាយទៅកាន់មនុស្សជាច្រើនទៀតអំពីស្ថានភាពរបស់ពួកគាត់។ គ្រូឧទ្ទេសសួរ: តើអ្នកគិតថានរណាខ្លះអាចជួយអ្នកបាន? គ្រូឧទ្ទេសបង្កើតបញ្ជីដើម្បីសរសេរគំនិតរបស់សិក្ខាកាមដាក់លើក្តារខៀន ហើយបង្កើតកូឡោនទំនេរទីពីរនៅក្បែរនោះ។

នៅពេលបំពេញបញ្ជីរួចហើយ គ្រូឧទ្ទេសអាចសួរសិក្ខាកាមអំពីប្រភេទបញ្ហាដែលពួកគេអាចនិយាយទៅកាន់មនុស្សទាំងអស់នេះ ហើយសរសេរឈ្មោះម្តងមួយៗនៅលើបញ្ជី។ គ្រូឧទ្ទេសគួរបញ្ជាក់ថាមធ្យោបាយដំបូងគេនិងសំខាន់បំផុតក្នុងការដោះស្រាយគឺត្រូវពិភាក្សាជាមួយក្រុមបង្រៀន។ គ្រូឧទ្ទេសម្នាក់ផ្សេងទៀតសរសេរគំនិតរបស់សិក្ខាកាមនៅជាប់នឹងឈ្មោះមនុស្សនីមួយៗលើបញ្ជី។

ចម្លើយរំពឹងទុក.......

| មនុស្សដែលអាចជួយ | ការងារដែលត្រូវជួយ...(ឧទាហរណ៍) |
|---|---|
| គ្រូបង្រៀនក្នុងក្រុម | *បញ្ហាជាច្រើនអាចដោះស្រាយបាននៅក្នុងក្រុមគ្រូបង្រៀន។ បញ្ហាការងារក្នុងថ្នាក់រៀន តួនាទី ការទទួលខុសត្រូវ បញ្ហាក្នុងការរៀនសូត្ររបស់កុមារម្នាក់ៗ បញ្ហាវិន័យក្នុងការសិក្សារបស់កុមារ បញ្ហារបស់អ្នកសម្របសម្រួលភាសាក្នុងការស្វែងយល់កម្មវិធីសិក្សា និងខ្លឹមសារមុខវិជ្ជានីមួយៗ បញ្ហាក្នុងការទំនាក់ទំនង បញ្ហាទាក់ទងខាងវប្បធម៌...* |
| អ្នកសម្របសម្រួលភាសា និងក្រុមគ្រូបង្រៀនផ្សេងទៀត | *បញ្ហាក្នុងថ្នាក់រៀន (សូមមើលខាងលើ)-បើសិនជាមានអ្នកសម្របសម្រួលភាសា/ក្រុមគ្រូបង្រៀនផ្សេងទៀតនៅសាលារៀននោះវាជាការល្អមួយដែលអាចជួបជាមួយពួកគាត់ដើម្បីពិភាក្សារកដំណោះស្រាយ* |
| នាយកសាលារៀន | *ជាអ្នកជួយអនុម័តឱ្យឈប់សម្រាកនៅពេលមានជំងឺ ឬនៅពេលមានទុក្ខធុរៈក្នុងគ្រួសារ បញ្ហាកុមារដែលមានទាក់ទងដល់ឪពុកម្តាយ បញ្ហាទាក់ទងជាមួយក្រុមបង្រៀន បញ្ហាទាក់ទងនឹងការបង្រៀន និងការសិក្សា ឬវិន័យដែលក្រុមគ្រូបង្រៀនមិនអាចដោះស្រាយបាន។* |
| គណកម្មការកម្រងសាលារៀនមូលដ្ឋាន | *បញ្ហាទាក់ទងនឹងការបើកប្រាក់ឧបត្ថម្ភ លក្ខខណ្ឌការងារ* |
| បុគ្គលិកអេស្កាប់ | *បញ្ហាទាក់ទងជាមួយតួនាទី និងការទទួលខុសត្រូវនៅក្នុងថ្នាក់រៀន បញ្ហាបច្ចេកទេសទាក់ទងការបង្រៀន និងរៀន* |
| បុគ្គលិកសមាគមន៍យុវជនឥស្លាមកម្ពុជា | *បញ្ហាក្នុងការទំនាក់ទំនង បញ្ហាទាក់ទងវប្បធម៌ខ្មែរ-ឥស្លាម និងភាសា បញ្ហាលំបាកដែលអ្នកសម្របសម្រួលភាសាមិនអាចប្រាប់សាលារៀន ឬបុគ្គលិកអេស្កាប់ដោយផ្ទាល់បាន* |

គ្រូឧទ្ទេសសន្និដ្ឋានបញ្ចប់ដោយត្រួតពិនិត្យព័ត៌មានដែលបានសរសេរនៅក្នុងតារាងខាងលើឡើងវិញ។

**សម្រាកពេលព្រឹក**

**៥. ការសរសេរអំពីការពណ៌នាការងារ ៣០ នាទី**

**សកម្មភាពចម្បង:** ការពិភាក្សាក្រុម និងការរិះគិតថ្មីពីការពណ៌នាការងារ

**ការរៀបចំ និងសម្ភារៈ:** តារាងអំពីការពណ៌នាការងាររបស់អ្នកសម្របសម្រួលភាសា

**គោលបំណង:** ដើម្បីជួយអ្នកសម្របសម្រួលភាសាឱ្យប្រមូលគំនិត និង យល់ច្បាស់អំពីតួនាទីរបស់ពួកគាត់តាមរយៈព័ត៌មានផ្តល់ឱ្យកាលពី៣ថ្ងៃមុន។

គ្រូឧទ្ទេសនិយាយថាៈ នៅក្នុងសកម្មភាពចុងក្រោយសិក្ខាកាមនិងផ្តល់គំនិតរបស់ពួកគាត់អំពីការពណ៌នាការងារសម្រាប់អ្នកសម្របសម្រួលភាសា ដោយសរសេរលំអិតនៅលើក្រដាសផ្ទាំងធំ ។

គ្រូឧទ្ទេសប្រាប់ឱ្យសិក្ខាកាមបង្កើតជារង្វង់មូលដោយមានតារាងធំមួយនៅចំកណ្តាល ឬនៅលើក្តារខៀនដោយឱ្យសិក្ខាកាមអង្គុយជុំវិញ ។ គ្រូឧទ្ទេសជួយសិក្ខាកាមដើម្បីធ្វើការទៅតាមចំណុចទាំងឡាយនៅលើតារាងម្តងមួយចំណុចដោយបំពេញចន្លោះ

(ចូរមើលទំរង់ និងឧទាហរណ៍ចម្លើយខាងក្រោម) ។

| មុខងារៈ *អ្នកសម្របសម្រួលភាសា* | | | |
|---|---|---|---|
| ឈ្មោះអ្នកសម្របសម្រួលភាសា | | | |
| ឈ្មោះគ្រូបង្រៀន | | | |
| រយៈពេលធ្វើការងារ | | | |
| ម៉ោងធ្វើការ | | | |
| ទីកន្លែងធ្វើការ | | | |
| ភូមិ | ឃុំ | ស្រុក | ខេត្ត |
| | | | |
| លក្ខណៈសម្បត្តិ | • *ចេះនិយាយភាសាខ្មែរ-ឥស្លាម និងភាសាខ្មែរ*<br>• *មានទីលំនៅនៅក្បែរកន្លែងធ្វើការ (សាលារៀន)*<br>• *មានបទពិសោធន៍ជាឪពុកម្តាយ/ជីដូនជីតា ឬអ្នកថែរក្សាក្មេង*<br>• *មានចំណាប់អារម្មណ៍ក្នុងការសិក្សាអប់រំ និងពេញចិត្តក្នុងមុខតំណែងនេះ*<br>• *ត្រូវបានស្វែងរក និងអនុម័តដោយសហគមន៍* | | |

| | |
|---|---|
| ភារកិច្ច | • *មកសាលារៀនជារៀងរាល់ថ្ងៃពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយ*<br>• *ជួបជាមួយគ្រូបង្រៀនដើម្បីឱ្យដឹងពីផែនការបង្រៀនប្រចាំថ្ងៃ*<br>• *ផ្តល់ដំបូន្មានឱ្យគ្រូបង្រៀនអំពីបញ្ហាភាសា និងវប្បធម៌*<br>• *ជួយកុមារដែលមិនចេះនិយាយភាសាខ្មែរពីកំណើត ជាលក្ខណៈបុគ្គល ឬជាក្រុមតូចៗ*<br>• *ជួយកុមារដែលមិនចេះនិយាយភាសាខ្មែរពីកំណើត ដោយពន្យល់ពីសេចក្តីណែនាំថ្នាក់រៀន (ដោយផ្ទាល់មាត់ ឬដោយសរសេរ)*<br>• *ជួយកុមារដែលមិនចេះនិយាយភាសាខ្មែរពីកំណើតដោយពន្យល់ពីសម្ភារសិក្សា (ឧ. ខ្លឹមសារសៀវភៅសិក្សា និងកិច្ចការ)*<br>• *ស្តាប់និងឆ្លើយសំនួររបស់កុមារដែលមិនចេះនិយាយភាសាខ្មែរពីកំណើត និងអាចផ្តល់សំនួរនេះទៅគ្រូបង្រៀនបើសិនជាចាំបាច់*<br>• *ជួយកុមារផ្សេងៗទៀតដែលជួបការលំបាកក្នុងការសិក្សា ជាពិសេសកុមារី កុមារអាយុច្រើន និងកុមាររៀនយឺត ។* |
| ទទួលខុសត្រូវចំពោះ | *គណៈកម្មការសាលារៀន នាយកសាលារៀន* |
| ប្រាក់ខែ | *១៥ ដុល្លាក្នុងមួយខែ* |
| | |

## ៦. ការគិតគូរទៅថ្ងៃអនាគតចំពោះអ្នកសម្របសម្រួលភាសា ៣០ នាទី

**សកម្មភាពចម្បង:** ការបង្ហាញរបស់គ្រូឧទ្ទេស

**ការរៀបចំ និងសម្ភារៈ:** ផែនការរបស់គ្រូឧទ្ទេស

**គោលបំណង:** ដើម្បីប្រាប់សិក្ខាកាមអំពីលទ្ធភាពនៃរបត់ និងការគិតគូរក្នុងពេលបច្ចុប្បន្ននេះរបស់ក្រសួងអប់រំ យុវជន និងកីឡាអំពីរបៀបក្នុងការបញ្ចូលការអប់រំខាងភាសាកំណើតទៅក្នុងសាលារៀនរដ្ឋនៅក្នុងប្រទេសកម្ពុជា ។

គ្រូឧទ្ទេសនិយាយថា: ដូចដែលបានពិភាក្សានៅក្នុងដំណាក់កាលបង្រៀនកាលពីព្រឹកមិញផងដែរថា អេស្តាប់ចាប់អារម្មណ៍ចំពោះលទ្ធផលនៃកម្មវិធីសាកល្បងអ្នកសម្របសម្រួលភាសា ពីព្រោះវាជាគំនិតមួយដែលអាចប្រើប្រាស់នៅក្នុងកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ។ គ្រូឧទ្ទេសសួរថា: តើអ្នកអាចគិតថាមានកន្លែងណាទៀតនៅក្នុងប្រទេសកម្ពុជាដែលអាចប្រើប្រាស់អ្នកសម្របសម្រួលភាសាបាន? ចម្លើយរំពឹងទុក: ក្នុងតំបន់ដែលមានជនជាតិភាគតិចដូចជា ខេត្តមណ្ឌលគីរី និងខេត្តរតនគីរី ។

គ្រូឧទ្ទេសនិយាយថាៈ វាជាការលំបាកណាស់សម្រាប់កុមារដែលមិនចេះនិយាយភាសាខ្មែរជាភាសាកំណើតឱ្យធ្វើកិច្ចការបានល្អនៅកម្រិតបឋមសិក្សា ដើម្បីបន្តទៅមធ្យមសិក្សា និងបន្តទៅការសិក្សានៅសាកលវិទ្យាល័យ។ ក្រសួងអប់រំបានទទួលស្គាល់បញ្ហានេះដែលជាចំណែកមួយរបស់ប្រទេសកម្ពុជាក្នុងការសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា ហើយក៏កំពុងព្យាយាមរកមធ្យោបាយផ្សេងៗដើម្បីជួយកុមារទាំងនេះ។

គ្រូឧទ្ទេសនិយាយថាៈ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយផ្សេងៗទៀតគឺត្រូវលើកទឹកចិត្តឱ្យមានការប្រើប្រាស់ភាសាកំណើតរបស់កុមារនៅក្នុងឆ្នាំសិក្សាដំបូងៗនៅបឋមសិក្សាគឺអាចពីថ្នាក់ទី១-៣។ ដើម្បីសម្រេចគោលបំណងនេះបានសាលារៀនត្រូវការគ្រូជាច្រើនដែលមានជំនាញចេះដឹងភាសាទីពីរ ឬមនុស្សទាំងឡាយដូចជាអ្នកសម្របសម្រួលភាសាដើម្បីជួយគ្រូបង្រៀនដែលចេះនិយាយតែភាសាខ្មែរ។ នៅពេលបច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡា មានមធ្យោបាយថ្មីមួយក្នុងការជួយអ្នកដែល និយាយភាសាផ្សេងៗឱ្យបានចូលទៅសិក្សានៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ ហើយពួកគាត់នឹងក្លាយជាគ្រូបង្រៀន-អ្នកអាចដឹងច្បាស់ពីមធ្យោបាយដែលអេស្កាប់ និងសមាគមន៍យុវជនឥស្លាមកម្ពុជាកំពុងធ្វើការនៅក្នុងខេត្តកំពង់ចាមលើបញ្ហានេះហើយអេស្កាប់ ក៏កំពុងជួយជនជាតិភាគតិចនៅក្នុងខេត្តក្រចេះ និងមណ្ឌលគីរីឱ្យបានសិក្សាដើម្បីក្លាយជាគ្រូបង្រៀនផងដែរ។

ក្រសួងអប់រំបានហៅគោលវិធីនេះថាជាគោលវិធីមួយក្នុងការជួយកុមារឱ្យរៀនភាសាខ្មែរ និងរៀនបានពូកែនៅក្នុងប្រព័ន្ធអប់រំរដ្ឋដោយផ្តល់ជា"ស្ពាន" រវាងជីវភាពគ្រួសារនិងភាសាកំណើត ទៅនឹងជីវភាពសាលារៀននិងភាសាខ្មែរ។ អេស្កាប់សង្ឃឹមថាអ្នកសម្របសម្រួលភាសាអាចជួយកសាងស្ពាននេះ ដើម្បីធ្វើឱ្យកុមារខ្មែរ-ឥស្លាមរីករាយមកសាលារៀន ការសិក្សាទទួលបានលទ្ធផលល្អ និងអាចបន្តការសិក្សាទៅកម្រិតខ្ពស់ទៀត នៅពេលពួកគេធំឡើង។

## ៧. ការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល ៣០ នាទី

**សកម្មភាពចម្បង:** សេចក្តីផ្តើមរបស់គ្រូឧទ្ទេស សិក្ខាកាមបំពេញទំរង់វាយតម្លៃជាក្រុមតូច

**ការរៀបចំ និងសម្ភារ:** ឯកសារដែលបានរៀបចំ (ចូរមើលខាងក្រោម)

**គោលបំណង:** ដើម្បីទទួលយកគំនិតរបស់សិក្ខាកាមអំពីភាពច្បាស់លាស់ និងភាពមានប្រយោជន៍នៃវគ្គបណ្តុះបណ្តាល។

គ្រូឧទ្ទេសបង្ហាញឯកសារវាយតម្លៃ និងពន្យល់ពីរបៀបជ្រើសរើសចម្លើយ និងការឆ្លើយសំនួរនីមួយៗ។ គ្រូឧទ្ទេសរៀបចំសិក្ខាកាមជាក្រុមដែលមានគ្នា៣ឬ៤នាក់ដើម្បីបំពេញទំរង់នោះ។

(ឯកសារវាយតម្លៃ សូមមើលទំព័របន្ទាប់)

**ចប់សិក្ខាសាលាបណ្តុះបណ្តាល**

## ទំរង់វាយតម្លៃ

## បញ្ចប់វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលភាសា

កម្រិតនៃការវាយតម្លៃមាន៥ចំណុច-លេខ១បដិសេធខ្លាំង លេខ២បដិសេធតិចតួច លេខ៣កម្រិតមធ្យម លេខ៤វិជ្ជមាន និងលេខ៥ វិជ្ជមានខ្លាំង

**ការយល់ដឹងរបស់ពួកយើងចំពោះគំនិតសំខាន់ៗ និងខ្លឹមសារវគ្គបណ្តុះបណ្តាលគឺ**

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| មិនយល់ខ្លឹមសារ ជាច្រើន | យល់ខ្លឹមសារ មួយចំនួន | យល់កម្រិត មធ្យម | យល់បានច្រើន | យល់ស្ទើរតែគ្រប់ ខ្លឹមសារទាំងអស់ |

**តើមានខ្លឹមសារណាមួយដែលអ្នកពិបាកយល់ឬទេ?**

១.--------------------------------------------------------------------------------

២.--------------------------------------------------------------------------------

**គំនិតរបស់ពួកយើងចំពោះសកម្មភាពសិក្សា និងកិច្ចការទាំងឡាយនៅក្នុងវគ្គបណ្តុះបណ្តាលគឺ**

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| មិនមានប្រយោជន៍ ច្របូកច្របល់ | ជួនកាលច្របូកច្របល់ | មានកម្រិតមធ្យម | មានប្រយោជន៍ និងច្បាស់លាស់ | មានប្រយោជន៍ និងច្បាស់លាស់ណាស់ |

**តើមានសកម្មភាពសិក្សា កិច្ចការណាខ្លះដែលអ្នកគិតថាមានប្រយោជន៍ណាស់? ( មានប្រយោជន៍ច្រើនជាងសកម្មភាពសិក្សាផ្សេងៗ)**

១.--------------------------------------------------------------------------------

២.--------------------------------------------------------------------------------

**គំនិតរបស់ពួកយើងចំពោះសម្ភារដែលប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះគឺ**

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| ច្របូកច្របល់ណាស់ | ជួនកាលច្របូកច្របល់ | មានកម្រិតមធ្យម | ជាធម្មតា ល្អនិងច្បាស់លាស់ | ល្អ និងច្បាស់លាស់ ណាស់ |

**គំនិតរបស់ពួកយើងចំពោះការបង្រៀនរបស់គ្រូឧទ្ទេសក្នុងវគ្គបណ្ដុះបណ្ដាលនេះគឺ**

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| អន់ណាស់ | ជួនកាលអន់ | មានកម្រិតមធ្យម | ជាធម្មតាល្អ | ល្អណាស់ |

**តើនៅពេលឥឡូវនេះអ្នកមានអារម្មណ៍ជឿជាក់ដើម្បីធ្វើការជាអ្នកសម្របសម្រួលភាសាកម្រិតណា?**

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| មិនមានជំនឿចិត្តទាល់តែសោះ | មិនមានជំនឿចិត្តចំពោះចំណុចមួយចំនួន | មានកម្រិតមធ្យម | មានជំនឿចិត្តភាគច្រើន | មានជំនឿចិត្តណាស់ |

**តើអ្នកនៅមានសំនួរផ្សេងទៀតដែលត្រូវសួរដែរឬទេ?**

១.----------------------------------------------------------------------------------------

២.----------------------------------------------------------------------------------------

## ឯកសារសម្រាប់សិក្ខាកាម

វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលភាសា-អេស្តាប់

**ឯកសារៈ ការសង្កេតការបង្រៀននៅក្នុងថ្នាក់**

| សាលារៀន | គ្រូបង្រៀន | ថ្នាក់ទី | មុខវិជ្ជា | កាលបរិច្ឆេទ | ម៉ោង |
|---|---|---|---|---|---|
| | | | | | |

| |
|---|
| ១. តើគ្រូបង្រៀនបានធ្វើការជាមួយសិស្សក្នុងថ្នាក់ទាំងមូលឬជាមួយសិស្សម្នាក់ៗ? |
| ២. តើកុមារស្តាប់បានច្បាស់នៅមុនពេលពួកគេត្រូវធ្វើអ្វីមួយឬទេ? |
| ៣. តើប្រភេទការងារអ្វីខ្លះដែលកុមារបានធ្វើ? |
| ៤. តើកុមារធ្វើការជាក្រុមតូច ឬធ្វើការជាលក្ខណៈបុគ្គល? |
| ៥. តើមានកុមារនៅក្នុងថ្នាក់រៀនខ្លះទេដែលមិនដឹងថាត្រូវធ្វើអ្វី? |
| ៦. តើអ្នកដឹងដោយរបៀបណាថាពួកគេមិនដឹងថាត្រូវធ្វើអ្វី? |
| ៧. តើគ្រូបង្រៀនបានធ្វើអ្វីខ្លះដើម្បីជួយកុមារទាំងអស់នេះ? |
| ៨. តើមានកុមារខ្លះទេដែលបានជួយកុមារផ្សេងទៀតនៅក្នុងថ្នាក់រៀន? |

| **មុខងារ:** អ្នកសម្របសម្រួលភាសា | | | |
|---|---|---|---|
| ឈ្មោះអ្នកសម្របសម្រួលភាសា | | | |
| ឈ្មោះគ្រូបង្រៀន | | | |
| រយៈពេលធ្វើការងារ | | | |
| ម៉ោងធ្វើការ | | | |
| ទីកន្លែងធ្វើការ | | | |
| ភូមិ | ឃុំ | ស្រុក | ខេត្ត |
| | | | |
| លក្ខណៈសម្បត្តិ | -<br>-<br>-<br>-<br>-<br>-<br>- | | |
| ភារកិច្ច | -<br>-<br>-<br>-<br>-<br>-<br>-<br>-<br>-<br>-<br>- | | |
| ទទួលខុសត្រូវចំពោះ | | | |
| ប្រាក់ខែ | | | |
| | | | |